ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

RÉGIE
DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចេញពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

---

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ ស៊ូរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

---

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

ព្រះអាចារ្យ រស់-កោ វត្តកោះព្រះ
ភ្លើង ក្រុងភ្នំពេញ — ការសិក្សា (តមកនិងចប់) . . . . . . . ៣៣៧
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម — វិធីរក្សារាងកាយ តម្រូវតាមសេចក្ដីត្រូវការ
របស់ធម្មជាតិ (តមក) . . . . . . . ៣៤៩
ឃុនសុន្ទរមេធី ញូង-សឿន — ឯកសៈហស្សរាត្រី ភាគទី ១៣ (តមកនិងចប់) ៣៥៧

*ផ្នែកសាសនា*

ព្រះគ្រូបញ្ញាសិរិត កៅ-ស៊ុម
គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ — យុវចរិយាកថា . . . . . . . . . . . ៣៦៩
ព្រះមហា ប៊ុណ្ណ-សុម្ភាត — សេចក្ដីដំណាលអំពីទេវបុត្តមារ និងព្រះថេរៈ
ព្រះនាមឧបគុប្តៈ (តមកនិងចប់). . . . ៣៨១

---

ឆ្នាំទី ១៩ — លេខ ៧ ខែកក្កដា (ស៊ីយេត) ឆ្នាំ ១៩៤៧ — ដំឡៃជាវ ១ ឆ្នាំ ៣៥ រៀល

## ការសិក្សា

### ព្រះអាចារ្យ ស៊ុ-កោ (កោវិទបណ្ឌិត)

(តមកពីលេខមុន)

ដល់ជាន់បរិញ្ញា(១) (Licence), វិញ្ញា(២) (Doctorat); និង អគ្គញ្ញា(៣) (Agrégation) ជាដើម ឲ្យប្រហែលនឹងមហាវិទ្យាល័យក្នុងនានាប្រទេស ដើម្បីឲ្យអ្នករៀនបានសម្រេចការសិក្សាជាន់ឧត្តមបាន ក្នុងប្រទេសយើងឯង ។

៤– ក្នុងចំណែកឧបករណ៍ការសិក្សា ដូចយ៉ាងសៀវភៅ, បណ្ណាល័យ ហិរញ្ញវត្ថុ, កីឡា, យុវបរិយោ និងសាយបុត្តិ ជាដើម គួរខំជាតឲ្យមានផ្សាយច្រើនពាលីតែល្មមដល់សេចក្ដីត្រូវការ ។

៦– គួរឧបត្ថម្ភការសាសនា ដែលជាបច្ច័យសំខាន់ក្នុងការអប់រំមនុស្សធម៌ឲ្យសម្រេចប្រយោជន៍នៃការអប់រំខាងនេះឡើង ។ ក្រសួងធម្មការនិងសាសនសិក្សាធិការ គួរតាំងបង្កើតឲ្យមានវៃចសម្រាប់រៀន និងបណ្ណាល័យ ឬ ធម្មមន្ទីរឲ្យបានច្រើនវត្ត តាមវត្តដែលគួរតាំងឲ្យមាន និងគួរបាត់តាំងសាលារៀនបរិយត្តិវិជ្ជាខាងផ្នែកធម្មៈ(៤) ខាងផ្នែកបាលី(៥)

---

១-២-៣- អ្នកមានបរិញ្ញាបត្រឧត្តមសិក្សាទាំងនេះហៅថា « បរិញ្ញូ (Licencié), វិញ្ញូ (Docteur) អគ្គញ្ញូ (Agrégé)" ឬនឹងហៅថា «នីតិបណ្ឌិត; ធីរបណ្ឌិត ឬ សុធីរៈ អគ្គបណ្ឌិត» ក៏បាន ។ ៤ ហៅថា «ធម្មសិក្សា» ។ ៥ ហៅថា "បាលីសិក្សា" ឬ បរិយត្តិសិក្សា ។

ឲ្យបរិបូណ៌ ដើម្បីឲ្យព្រះសង្ឃគ្រប់រូបគ្រប់វ័យរៀនបានតាមស្មើគ រូបត្រូវចាត់តាំងប្រកាសបញ្ញត្តជាព្រះរាជក្រម បង្ខិតបង្ខំឲ្យព្រះសង្ឃគ្រប់អាពមទទួលការសិក្សាធម្មវិន័យបរិយត្តិ តាមសាលាដែលចាត់តាំងទិនទានពុំបាន ។ សម្បូរក៏សាលារៀនបឋមសិក្សាទូទៅ ក៏ត្រូវតាំងឲ្យមានការបង្រៀនផ្លូវសាសនា ខ្វះផងទានពុំបាន ដើម្បីបណ្តុះនិស្ស័យក្មេងឲ្យស្រឡាញ់សាសនារបស់ខ្លួនគឺព្រះពុទ្ធសាសនាផងដើម្បីឲ្យក្មេងបេះដូងប្រព្រឹត្តតាមមនុស្សធម៌ផងបរិយាល្អ (ធម្មចរិយា) ។

គ្រោងការទាំងអស់នេះ ទីងត្រូវដើរទៅព្រមគ្នា ដើម្បីជាឧបករណ៍ដល់គ្នានឹងគ្នា ហើយត្រូវកតរបោត់ធ្វើតាមកម្លាំងហិរញ្ញវត្ថុដែលមានលម្មទីងធ្វើបាន ។

ក្រៅពីគ្រោងការទាំង២មាត្រានេះ នៅមាននយោបាយសំខាន់មួយផ្លូវទៀត ដែលគួរទិតដល់ទីងត្រូវចាត់តាំងឲ្យមានរបៀបវិសេសឡើងដោយខានពុំបាន គឺត្រូវលើកដំកើងកិត្តិយសរបស់គ្រូបង្រៀនឲ្យមានឋានន្តរស្មើនឹងមន្ត្រីរាជការក្នុងក្រសួងឯទៀតៗ ព្រមទាំងឲ្យមានបៀ-វត្ស ឬមាសិកា (ប្រាក់ខែ) ល្មមចិញ្ចឹមជីវិតបានយ៉ាងស្រួលជាឯកបុគ្គល ទោះជាត្រូវប្រភេទណាក៏ដោយ កុំឲ្យខ្វះខាត ឬត្រូវជាប់ត្រដួសដែលជាហេតុឲ្យខ្សោយកម្លាំងគ្មានសមត្ថភាពក្នុងការបង្រៀនឬរត់ចោលក្រសួង ។ ហេតុនេះ រដ្ឋាភិបាលទើបត្រូវរៀបចំតែងតាំងព្រះរាជក្រឹត្យលើកដំកើង

យសសក្តិនិងបៀវត្ស ឬមានសិស្សរបស់ខ្លួនដែលជាអាចារ្យបង្រៀន ឲ្យបានស្រួលបួលជាបំផុត ។

## សាមញ្ញសិក្សា និង វិសាមញ្ញសិក្សា

សាមញ្ញសិក្សា បានដល់ការសិក្សាវិជ្ជាសាធារណៈ ដែលជាវិជ្ជាប៉ែកខាងចំណេះទូទៅ ចាប់បង្រៀនតាំងពីថ្នាក់កុមារបាលរហូតទៅ គឺការសិក្សាអក្សរសាស្ត្រ, លេខសាស្ត្រ, នព្វន្តសាស្ត្រ, ធរណីប្រមាណសាស្ត្រ, ភាសាសាស្ត្រ, និរុត្តិសាស្ត្រ, សព្ទសាស្ត្រ, ធម្មសាស្ត្រ, ភូមិសាស្ត្រ, ប្រវត្តិសាស្ត្រ, នីតិសាស្ត្រ, ឆន្ទសាស្ត្រ, កាព្យសាស្ត្រ, វិទ្យាសាស្ត្រ, តក្កសាស្ត្រ, សារីរសាស្ត្រ, វេជ្ជសាស្ត្រ, ភេសជ្ជសាស្ត្រ, សិល្បសាស្ត្រ, សង្គមសាស្ត្រ, រដ្ឋប្រសាសនសាស្ត្រ, យុទ្ធសាស្ត្រ, ព្យូហសាស្ត្រ, និងហោរាសាស្ត្រជាដើម ព្រមទាំងគរុវិជ្ជា, បរមត្ថវិជ្ជា, ធាតុវិជ្ជា, អនាម័យវិទ្យា, សុខវិទ្យា, បុរាណវត្ថុវិជ្ជា និងវរលេខវិជ្ជាជាដើម ។

វិសាមញ្ញសិក្សា បានដល់ការសិក្សាវិជ្ជាការជីព ដែលចាត់ឲ្យសមដល់ភូមិប្រទេស ដូចវិជ្ជាកសិកម្ម, ពាណិជ្ជកម្ម, ហត្ថកម្ម, សិប្បកម្ម, ទេសព្វាហកម្មជាដើម និងវិជ្ជាសម្រាប់គ្រួសារផ្សេង ៗ ។

បុគ្គលគ្រប់ៗគ្នា គួរបានទទួលសាមញ្ញសិក្សាឲ្យត្រឹមល្មមនឹងវិជ្ជាប៉ែកខាងវិសាមញ្ញសិក្សា ដែលខ្លួនស្ម័គ្ររៀនទៅ ។

## ការសិក្សាភាសានានាប្រទេស

អនុលោមរបៀបការសិក្សាជាន់ឧត្តម ត្រូវរៀនភាសានានាប្រទេស ដែលជាភាសាបច្ចុប្បន្ន ឬភាសាបុរាណចំនួន យ៉ាងតិច ២ ភាសា ។ កំណត់ភាសានានាប្រទេសឲ្យជ្រើសរើសរៀនតាមពេញចិត្តដូចនេះ

ក) ភាសាបច្ចុប្បន្ន: បារាំងសែស អង់គ្លេស អាមេរិកាំង ចិន យួន ថៃ ។

ខ) ភាសាបុរាណ : បាលី សំស្ក្រឹត ឡាតាំង ។

ត្រូវចាប់ផ្ដើមរៀនភាសានានាប្រទេសទី ១ តាំងពីប្រថមវៀន ប្រថមសិក្សាជាន់ខ្ពស់ (ថ្នាក់ឆ្នាំទី ១ នៃឧត្តម) ចំណែកចាប់ផ្ដើមរៀនភាសានានាប្រទេសទី ២ តាំងពីប្រថមទុតិយភូមិ (Première secondaire) នៃទុតិយសិក្សា (Baccalauréat) ។ តែអ្នករៀនការលើបានរៀនចប់ត្រឹមតែជាន់វិសាមញ្ញសិក្សានៃប្រថមវិសាមញ្ញចំនីមធ្យមវិសាមញ្ញ ត្រូវវែលករៀនភាសាចិនសម្រាប់ឲ្យស្រួលខាងពាណិជ្ជកម្ម ។

## ការបាក់ជាន់សិក្សា

ការបាក់ជាន់សិក្សាតាមវិធីការសិក្សារបស់ជាតិនោះ ខ្ញុំពុំបានសរសេរទុកក្នុងនេះទេ ព្រោះរឿងនេះ លុះតែសរសេរជាសៀវភៅមួយផ្សេងច្បាស់លាស់ការយ៉ាងល្អិតពីពាក្យអធិប្បាយ, វិធីបាក់ជាន់សិក្សាមិនកំណត់អាយុអ្នកចូលរៀនជាដើមទេបាន ហើយលុះតែបានខ្ញុំ

អនុញ្ញាតពីក្រសួងសិក្សាធិការនិងសាសនសិក្សាធិការផង ។ ប៉ុន្តែខ្ញុំនឹងសរសេរតែពីផែនទីការសិក្សា នៅទាន់ចុង ដែលមានទាក់ទងដោយរឿងនេះខ្លះ ៗ តែមិនមែនជាការបាត់ជាន់សិក្សាដោយចំពោះនោះទេ ។

## ឧបករណ៍ការសិក្សា

ឧបករណ៍ការសិក្សាមានច្រើនយ៉ាង តែក្នុងទីនេះនឹងសូមនិយាយតែឧបករណ៍ដែលសំខាន់ៗ ប៉ុណ្ណោះ គឺ: កាយឫទ្ធិ; យុវបរិយា, ពារញ្ញ-រត្ត, បណ្ណាល័យ, ថែបរៀននឹងកីឡាជាដើម សុទ្ធតែជាឧបករណ៍ការសិក្សា ដែលអាចនឹងជួយឲ្យការសិក្សាទាំងចំណែកសាមញ្ញនិងវិសាមញ្ញ មានដំណើរទៅខ្ពស់ផុតចំណានបាន ។ របស់ទាំងនេះជាឧបករណ៍យ៉ាងណា ? នឹងបានអធិប្បាយជាយ៉ាងៗ ដូចតទៅនេះ

កាយឫទ្ធិ ដើម្បីនឹងហ្វឹកហាត់ក្មេង ទាំងក្នុងចំណែកផ្លូវកាយ និងក្នុងចំណែកចិត្ត ដើម្បីឲ្យចេះដឹងអត់ធន់តស៊ូសេចក្ដីលំបាកវេទនា យ៉ាងច សម្រាប់កូនប្រុស កាលធំឡើងនឹងធ្វើនាទីជាជនខ្មែរគ្រប់មនុស្ស ត្រូវប្រព្រឹត្តឲ្យជាប្រយោជន៍ដល់ជាតិ, ដល់ប្រទេស និងដល់ស្រុកកំណើតរបស់ខ្លួន នឹងត្រូវហ្វឹកហាត់បណ្ដុះចិត្តជាមុនតាំងពីនៅក្មេងឲ្យហើយ ព្រោះក្មេងប្រៀបដូចឈើខ្ចី នឹងដាក់ពត់ឲ្យជារូបយ៉ាងណា ក៏បានដោយងាយ

ហើយល្អមើលផង បើបណ្ដោយឲ្យចាស់សិនហើយ ដល់នឹងពត់ក៏ត្រូវពេលក្រោយ មុខជានឹងបែកបាក់ប្រេះឆាក្នុងខណៈ ដែលពត់យ៉ាងណា សន្ដានមនុស្សក៏ដូចគ្នា ។

សរុបសេចក្ដីថា ការកសាងយុវជនយុវនារីទៀង ដោយបំណងនឹងអប់រំក្មេងឲ្យមានលក្ខណៈ សមនាទីជាពលរដ្ឋល្អតទៅខាងមុខ ដោយការហ្វឹកហាត់ក្នុងផ្លូវផ្សេងៗ និងរួបរួមជាខ្ទង់ៗ បាន ៤ ខ គឺ

១- ហ្វឹកហាត់បញ្ញា និងសេចក្ដីប្រព្រឹត្ត ។

២- ហ្វឹកហាត់ដៃឲ្យចេះដឹងប្រកបការងារជាប្រយោជន៍ ។

៣- ហ្វឹកហាត់ចិត្តឲ្យមានសេចក្ដីមេត្តាករុណា ធ្វើការជួយឈឺឆ្អាលអ្នកដទៃ ។

៤- ហ្វឹកហាត់កាយឲ្យមាំទាំវែងវ៉ៃស្លូតជំនាញរហ័សរហួន ។

**យុវបរិយា** ដើម្បីនឹងបណ្ដុះកប់ខ្ពស់ក្នុងចិត្តចំពោះការស្រឡាញ់ នឹងគុណធម៌មានប្រការផ្សេងៗ គឺឧត្ដមគតិ ហើយនឹងវិធីការនៃកិច្ច ខិតខំសខ្លួនដាក់ខ្លាំងការងារដោយចំពោះ ដល់ក្មេងទាំងឡាយ ដើម្បីជាការពិចារណាក្នុងអនាម័យរបស់ខ្លួនឯង នឹងរបស់អ្នកដទៃប្រការ ១, សេចក្ដីចូលចិត្តក្នុងការទទួលយកនូវការទទួលខុសត្រូវ ក្នុងនាទីរបស់ប្រជាជនប្រការ ១; ការបណ្ដុះនឹងរក្សាទុកនូវធម្មារម្មណ៍ ប្រព្រឹត្តទៅដើម្បីមេត្តា-ធុរៈគ្រោះដល់ជាតិរបស់ខ្លួននឹងនានាជាតិរហូតដល់លោកប្រការ ១ ។

តាមបរិយាយដែលលើកមកនេះ កាយឫទ្ធិនៃយុវចរិយាទើបជាគ្រឿងអប់រំឧបនិស្ស័យ ឲ្យដឹងវិន័យ, នាទី ហេតុផលដែលគាប់ដឹងទទួលខុសត្រូវក្នុងនាទីរបស់ខ្លួន (បរិយាសិក្សា) ។ ក្រៅពីនោះនៅជាគ្រឿងជួយជ្រោមជ្រែងអនាម័យ គឺឲ្យចេះដឹងរក្សាខ្លួនឲ្យប្រាសចាករោគ ឲ្យមានកម្លាំងកាយមាំមួន ។ល។ (ពលសិក្សា) ។

ហិរញ្ញវត្ថុ តាមនាទីក្រសួងសិក្សាធិការដាក់របៀបឲ្យសោហ៊ុយរៀន គឺដើម្បីនឹងឲ្យជាគ្រឿងជន្ទូចិត្តឲ្យក្មេងព្យាយាមរៀន និងជាគ្រឿងទំនុកបំរុងអ្នកដែលជាប់សោហ៊ុយ បើជាក្មេងល្អ មិនបានមានឱកាសរៀនសូត្រឲ្យសមដល់អត្តភាពនិងភូមិបញ្ញារបស់ខ្លួន ។ ហេតុនេះការបង្កើត «កម្ពោជសិស្សសមាគម» ឬ «ក្រុមសន្ធានិស្សិតខ្មែរ» ដើម្បីឃោសនាប្រមូលហិរញ្ញវត្ថុទុក បំរុងជួយនិស្សិតខ្មែរអ្នកទីទ័លក្រឲ្យមាន «សោហ៊ុយរៀន» បន្តចំណេះវិជ្ជាឲ្យបានដល់ត្រើយ ជាការមួយយ៉ាងសំខាន់ ព្រោះជាឧបករណ៍ការសិក្សា គួរតែបង្កើតឲ្យមាននិងមានពុំបាន ដើម្បីជួយបំពេញកង្វះការចំណាយរបស់ក្រសួងសិក្សា-ធិការកុំឲ្យខ្វះខាត កុំឲ្យទទួលបន្ទុកចំណាយធ្ងន់ពេក ឲ្យមានសោហ៊ុយគ្រប់គ្រាន់ ។ ខាងផ្នែកសាសនា ក្រសួងសាសនសិក្សាធិការគួរតែងបង្កើតឲ្យមាន «ពុទ្ធិកសមាគម» ទៀត ដើម្បីឃោសនាប្រមូលបច្ច័យទុកឲ្យបានច្រើន ប្រយោជន៍ជួយទំនុកបំរុងការសាសនា ដូចយ៉ាងការ

មណ្ឌលបណ្ណាលធម្មវិទ័យ ដោយតាំងបង្កើត ឬជួយឧបត្ថម្ភសាលាធម្ម-សិក្សា ឬ សាលាបរិយត្តិសិក្សាឲ្យមានបរិបូណ៌ទាំងឲ្យបានរីកចំរើន; ការបញ្ជូនព្រះសង្ឃឲ្យទៅរៀនវិជ្ជាជាន់ខ្ពស់ នៅសាលាជាន់ខ្ពស់នានាប្រទេស ដើម្បីយកមកបង្រៀនក្នុងសាលាបាលីជាន់ខ្ពស់ ឬ មហាវិទ្យាល័យពុទ្ធសាសនាក្នុងប្រទេសយើង និងការចាត់បញ្ជូនព្រះសង្ឃឲ្យត្រាច់រង្គាត់ទៅនៅប្រកាសសាសនាក្នុងនានាប្រទេសផងដែរ ។

**បណ្ណាល័យ** មន្ទីរសៀវភៅប្រៀបដូចជាទីសម្រាប់ទុកសព្វវិជ្ជានានា ដើម្បីឲ្យក្មេងស្រាវជ្រាវរកសេចក្ដីដឹងគឺវិជ្ជាបានគ្រប់វេលា ជាគ្រឿងលើកដម្កើងវិជ្ជាដែលរៀនមកនោះ ឲ្យចែករីកទូលំទូលាយចេញទៅ ទើបចាត់ជាបណ្ណាល័យជាឧបករណ៍ការសិក្សាមួយហោង ។

**បែបរៀន** សៀវភៅដែលជាបែបសម្រាប់រៀនទាំងសម្រាប់បង្រៀន មានច្រើនប៉ុន្មានក៏អាចឲ្យប្រយោជន៍ប៉ុណ្ណោះដែរ ក្មេងនឹងបានផ្សាំបណ្ដុះ ឬ បង្កើនវិជ្ជាគឺការរៀនសូត្ររបស់ខ្លួនឲ្យរីកទូលំទូលាយឡើង ព្រោះចំណេះដែលបានមកពីគ្រូក្នុងខណៈដែលរៀននោះ នៅមិនទាន់ល្មមដល់សេចក្ដីត្រូវការ រមែងភ្លេចភ្លាំងឬខ្វះខាតខ្វះជាដរាប ។ ដូច្នោះហើយ បានជាបែបរៀនជាឧបករណ៍ការសិក្សា ទំនងជាមួយគ្នានឹងមន្ទីរសៀវភៅ (បណ្ណាល័យ) ។

កីឡា ធម្មតាក្មេងតែងពេញចិត្តនឹងការលេង នឹងបង្គាប់ឲ្យនៅស្ងៀមៗ មិនបាន ព្រោះមិនជាការយកយោងសន្តានរបស់ក្មេងឲ្យល្មមសមគួរ តែងតែបើកឱកាសបញ្ជាត់ឲ្យលេង ។ ប៉ុន្តែការលេង យើងត្រូវជ្រើសរើសយកតែកីឡាដែលមិនមានទោស ជាកីឡាបំណងយកទុបនិស្ស័យរបស់ក្មេងឲ្យចេះផ្ទឹងនាទីរបស់ខ្លួន, ស្រឡាញ់ពួកគណៈ មិនមើលឃើញដល់ខ្លួនម្នាក់ឯង ថែមទាំងបំរុងចិត្តថ្វើមកង្កាយដែលបំណងទៅកងផ្សំជាមួយគ្នា ឲ្យដើរត្រសង់ឆ្ពោះទៅតាមការសិក្សា រហូតដល់ត្រើយនៃការរះដឹង ។ ហេតុនោះ កីឡាទើបចាត់ថាជាឧបករណ៍ការសិក្សា ដោយន័យដូចពោលមកហើយនេះឯង ។

## អវសានកថា

ឈលបើនិយាយដល់រឿងកិត្តិយសរបស់ប្រទេសជាតិហើយ គឺជាធម្មតា មិនថាជាតិណា សាសនាណា តែងមានបំណងដូចគ្នាតែមួយ គឺត្រូវការឲ្យប្រទេសជាតិរបស់ខ្លួន បានទទួលសេចក្ដីលើកតម្កើងឡើងជាជាតិដែលដល់ហើយនូវសេចក្ដីចំរើនរុងរឿងគឺអារ្យជាតិអារ្យប្រទេស តែដែលនឹងបានដោយលក្ខណៈដូចម្តេចខ្លះ? ទើបនឹងបានឈ្មោះថាជាប្រទេសជាតិដែលដល់ព្រមដោយអារ្យធម៌ ល្មមនឹងហៅថាអារ្យប្រទេស-អារ្យជាតិបាន? នោះយើងនឹងប្រៀបផ្ទឹមគ្នាបានតែមួយគ្រាៗ ថា: ប្រទេសនោះមានប្រជាជនច្រើន មានគមនាគមន៍ល្អបរិបូណ៌ មានផ្លូវថ្ន-

គំរៀបចំស៊ីវ៉ាច្រើន ឬមានប្រជាជនប្រុសស្រីតែងខ្លួនដើរលេងហ៊ុហាលាត ហើយស៊ីផឹកទូទៅគ្រប់ផ្លូវគ្រប់ទីកន្លែង; ត្រឹមប៉ុណ្ណោះល្មមហៅបានឬ? មិនបានទេឡើយ; គុណភាពសម្បូរនេះគេប្រើគ្រឿងសំគាល់សំដែងថា: ប្រទេសនោះ ជាតិនោះ ជាប្រទេសជាតិដែលចំរើនហើយ ក៏ជាមិនបាន ។ ចំណែកសំខាន់របស់ប្រទេសជាតិដែលនឹងហៅបានថា ជាប្រទេសជាតិដែលចំរើនហើយយ៉ាងពិតប្រាកដ នោះស្រេចនូវវិញ្ញាណរបស់ប្រជាជនទាំងអស់ទេតើ ! លោក-អ្នកដែលគិតមើលដែរឬ? សូម្បីប្រទេសនោះបរិបូណ៌ដោយថ្នល់ផ្លូវដើរ ពេញដោយផ្ទះថ្មីរៀបជាជួរ សម្បូណ៌ដោយពន្លឺស្មើរឡាលព្រាលផ្សាយទូទៅគ្រប់ផ្លូវគ្រប់ទីកន្លែង តែបើប្រជាជនរបស់ប្រទេសនោះ, ប្រែនតែមានសេចក្ដីប្រព្រឹត្តិខុស មានគ្រួផែកបង់ មានការប្រកាន់ពូជប្រកាន់គណៈ ចូលចិត្តទាំងហិង្សសង្កត់សង្កិនបៀតបៀនគ្នានូវគ្នា កាចហួសចេះ ស្លូតហួសហេតុ មានរឿងឫស្យាឈ្នានិសប្រកួតប្រណាំងគ្នាយ៉ាងគោលហាលនៅប្រចាំថ្ងៃ ស្រុកទេសពេញដោយពួកមិច្ឆាជីពនានាប្រការ... ដូច្នេះ នឹងហៅបានថាប្រទេសនោះជាប្រទេសចំរើនហើយម្ដេចកើត? មិនបានសោះឡើយ ។ គុណភាពដ៏ពិតមែនរបស់ប្រទេស ដែលសង្គមនឹងកើតជាម្ចាស់ថាជា 'សារៈ',

បាននោះ ក្នុងខាងដើម ត្រូវលើកយកសេចក្ដីប្រព្រឹត្តរបស់ប្រជាជន គ្រប់ៗគ្នា ដែលជាចំណែកមួយរបស់ជាតិឡើងពិចារណាជាមុនពេល គឺប្រជាជនពលរដ្ឋរបស់ប្រទេសនោះ សូម្បីមិនទាំងអស់ក៏ជាចំណែកច្រើន ត្រូវជាអ្នកទ្រទ្រង់នូវសីលធម៌ល្អ ជាអ្នកមានសម្មាជីពមានទុច្ចរិតធម្មជាចំណែកតិចបំផុតឬស្ទើរតែមិនមានឡើយ ដើម្បីទាំងមុខការប្រចាំកិច្ចរបស់ខ្លួនតាមឋានៈ ជាពលរដ្ឋល្អឬអន់អាច ផ្លូវការរបស់ប្រទេសក៏ដើរទៅដោយស្រួលជាប្រក្រតី ប្រាសចាកការកោលាហល ឬទទឹងទទ្ទង់មិនត្រូវទំនង ... ដូច្នេះ ទើបទឹងគាត់ថាជាគ្រឿងសំគាល់អាចដឹងបានថា ប្រទេសនោះដល់ហើយនូវការរក្ខបាន ។ ឯការមិនរៀបរយក្នុងកុម្មិកាគនៃប្រទេសនោះៗ ជាផលចំណែកមួយរបស់ការធ្វើផ្សងពិត្ត រតះប្រែគ្រឿងកំណត់នៃសេចក្ដីចំរើនមិនបាន ។

ចុះទឹងធ្វើដូចម្ដេចឲ្យបានប្រជាជនទៅជាពលរដ្ឋល្អបាន? បញ្ហានេះអ្នកណា ៗ ក៏ឆ្លើយបានថា ការសិក្សា តែម្យ៉ាងប៉ុណ្ណោះទើបទឹងធ្វើមនុស្សឲ្យទៅជាមនុស្សពេញលេញនឹមនុស្សយើងគ្រប់គ្នា ត្រូវតែសិក្សាអប់រំខ្លួនផ្លូវដែលត្រឹមត្រូវ តាំងពីវ័យនៅក្មេងឲ្យហើយ ដែលជាវ័យត្រូវតែបែកទុកចិត្តចំពោះការសិក្សាជាភាគសំខាន់តែម្យ៉ាង ។ ទីនេះ

យើងដល់មកបញ្ហាមួយទៀតថា  ចុះនរណាហ្នឹងជាអ្នកឲ្យការសិក្សា? បញ្ហានេះ  បើមានឱកាស  ខ្ញុំនឹងដោះស្រាយអធិប្បាយជូនលោក-អ្នកស្តាប់ ជាសេចក្តីពិស្តារក្នុង "ការសិក្សា ភាគទី ២" តទៅ ។ ភាគទី ១ នេះ  សូមសន្ទើបត្រឹមប៉ុណ្ណេះ ។

សូមប្រទីបទ្វីបអាស៊ីបានរុងរឿង!

សូមស្រុកខ្មែរបានថ្កុំថ្កើងទៀងដល់សិរ!

សូមសាសនាព្រះសម្ពុទ្ធតែស្ថិតស្ថេរ!

សូមល្បីកេរ្តិ៍ចិរកាលទៅអស់លោនយោន! ។

# វិធីរក្សាភាពកាយ

## តម្រូវតាមសេចក្ដីត្រូវការរបស់ធម្មជាតិ

## ហ្សង់តិពន្ធមន្ត្រី ញ៉ុក-ថែម ប្រែរៀបរៀង

(តមក)

---

ការធ្វើអាហារសម្រាប់បរិភោគងាយៗ ហើយតិចមុខនឹងចំនួនតែល្មមសមគួរ ហើយមិនបរិភោគដោយឥតរបៀបនោះជាការប្រយ័ត្នទ្រព្យសម្បត្តិបានច្រើនផង ហើយជាមិត្តរបស់អ្នកដែលមានចំណូលតិចផង ។ ការហាត់ទម្លាប់ខ្លួននឹងបិត្តគំនិត ឲ្យជាមនុស្សស៊ីងាយ ដេកងាយនេះជាការមានប្រយោជន៍ច្រើនណាស់ដល់ជីវិតរបស់យើង ។ ចុះអ្នកណាខ្លះហ៊ានកំចាំងថា ហេតុការណ៍របស់ជីវិត និងរបស់លោកនឹងគង់ទ្រង់នៅដដែលដោយឥតប្រែប្រួល ?- កាលដែលកើតសង្គ្រាមរាំងជប៉ុននឹងរុស្ស៊ីមានរឿងមួយដែលនាំឲ្យគេដំណាលសើច ក្នុងកាលតមកថា ពួករុស្ស៊ីទម្លាប់បរិភោគតែអាហារដាំខ្ពស់ ដែលមានសាច់ជ្រូកសាច់មាន់ សាច់គោ សាច់គោទឹករបស់វិសេសៗ ដទៃទៀតទាល់តែច្បាប់ខ្លួន ។ ណោះនោះមានទូកាសមួយដែលចនឹងទាហានរុស្ស៊ីល្មមក់យកំលាយចនឹងទាហានជប៉ុនបាន ឬល្មមចូលដណ្ដើមយកស្បៀងអាហារតែនឹងទាហាន

ជប៉ុនបាន ដោយចំណាំនិងយកស្បៀងអាហាររបស់ជប៉ុនមកបរិភោគឲ្យបានឆ្អែតស្កប់ស្កល់តាមចំណង់ដែលឃ្លានពីនាយមក លុះពួកទាហានរុស្ស៊ីយបានស្បៀងជប៉ុនមកហើយ ក៏ប្រែទឹកមុខកល់គ្នាខុសបំណងស្រឡះ ព្រោះចំណីអាហាររបស់ជប៉ុនមានតែសណ្តែក ល្ង បន្លែ និងបាយប៉ុណ្ណោះដែលពួកទាហានរុស្ស៊ីលេបពុំចូលឡើយ ទើបនាំគ្នាទុកឲ្យឃ្លានក្រៀមក្រពះដដែល ។ បំណែកខាងពួកទាហានជប៉ុនឈ្នះបើមានជ័យជំនះកងទ័ពរុស្ស៊ីវិញ ពួកទាហានជប៉ុនក៏គង់បានឆ្អែតស្កប់ស្កល់ ដោយបានអាហារដ៏មានឱជារសមកបរិភោគដែលគេបានដោយតម្រែ កងកងទ័ពទាហានជប៉ុន ។

## អាកាស

សេចក្តីសំខាន់របស់អាកាសនេះ ក៏មិនស្ទើរខុសប្លែកពីអាហារដែលយើងបរិភោគប៉ុន្មានទេ ។ បើយើងដាច់អាហារយើងក៏គោងតែស្លាប់ បើខ្វះអាកាសដកដង្ហើម យើងក៏គោងតែស្លាប់ដែរ ហើយឆាប់ស្លាប់ជាងអាហារផង ។ អាកាសដែលយើងប្រើដកដង្ហើមនេះប្រកបដោយធាតុផ្សេងៗជាច្រើនប្រការ ដូចជាឧក្ស៊ីហ្សែន ហ៊ីដ្រូហ្សែន និត្រូហ្សែន ឈរបោនជាដើម ។ ក្នុងបណ្តាធាតុទាំងនេះ ឧក្ស៊ីហ្សែនជាធាតុសំខាន់បំផុតសម្រាប់ជីវិត ។ ការទៅយកខ្យល់អាកាសដើម្បីឲ្យបានសេចក្តីសុខ

សប្បាយដល់រាងកាយនេះ ក៏គឺការស្រូបតែឱក្ស៊ីហ្សែនទៅតែងដែល មានឱក្ស៊ីហ្សែនខ្លះឯង ៗ ឯធាតុការបូនអាស៊ីត ជាធាតុដែលរាងកាយមិនត្រូវការឡើយ តែទុកជាយ៉ាងណាក៏ដោយ អាកាសដែលយើងដកដង្ហើមចូលទៅក្នុងសួតនេះ មិនដែលប្រាសចាកធាតុការបូនអាស៊ីតនេះសោះឡើយ ព្រោះដោយហេតុថា ធាតុនេះនៅមានប្រយោជន៍ជួយដាស់ឲ្យសួតធ្វើការតាមមុខក្រសួង ៗ

ឯអាកាសនឹងរាងកាយមានការទាក់ទងគ្នាជាប្រចាំ គឺខ្យល់អាកាសដែលយើងដកដង្ហើមចូលទៅតាមរន្ធច្រមុះនេះ ចូលទៅក្នុងថង់ខ្យល់ដែលមាននៅពេញខាងក្នុងសាច់សួត ហើយចាយចែកធាតុឱក្ស៊ីហ្សែនដល់សរសៃលោហិត ហើយផ្ទេរយកធាតុការបូនចេញមកពីសរសៃលោហិត ធ្វើឲ្យលោហិតដែលហូរចេញពីសួតទៅ ជប់លៀងបំរុងរាងកាយសព្វតែជាលោហិតល្អបរិសុទ្ធជានិច្ច ៗ គួរជ្រាបថា ធាតុការបូនអាស៊ីតនេះ ដែលត្រូវផ្ទេរចេញពីសរសៃលោហិត គឺជារបស់ដែលរាងកាយ ឥតត្រូវការ ហើយវាត្រូវចេញមកពីរាងកាយ មានទំនងដូចជាឧច្ចារៈនឹងបស្សាវៈដែរ គ្រាន់តែខុសគ្នាដោយលក្ខណៈប៉ុណ្ណោះ ៗ

ប្រសិនបើគិតមើលត្រិះរិះហើយ យើងក៏ដឹងខ្លួនថា ហាក់ដូចជារាងកាយយើងមិនដែលខ្វះខាតអាកាសសោះឡើយ ព្រោះនៅទីណា ៗ ក៏ដោយលើផ្ទៃពិភពនេះតែងមានអាកាសពាសពេញទូទៅ ៗ តែសុំកុំ

ចូលចិត្តដូច្នេះទៀយ ពិតមែនតែផ្ទៃពិភពនេះមានអាកាសទូទៅ តែគេគង់
យល់ថាអាកាសនេះប្រកបដោយធាតុច្រើនប្រការ ទើបគេអាចពោល
បានថានៅតំបន់នីមួយៗ តែងមានអាកាសធាតុប្រកបដោយគុណសម្បត្តិ
ផ្សេងៗគ្នា ។ ដូចជាតំបន់ដែលមានមនុស្សច្រើនណែនណាន់តាន់តាប់
អាកាសក្នុងតំបន់នេះមានគុណសម្បត្តិជាអាកាសមិនបរិសុទ្ធ ដោយហេតុ
មនុស្សគ្រប់ៗគ្នា ត្រូវការឲក្សីហ្សែនបញ្ចូលទៅក្នុងខ្លួន ហើយ
បញ្ចេញការបូនអាស៊ីតមកជាចំនួនច្រើនៗ ជាតិអាកាសបរិសុទ្ធក្នុងទី
ឯទៀតចូលមកជំនួសឲ្យបានទាន់គ្នា តែក្នុងតំបន់មួយទៀតដែលមាន
មនុស្សនៅតិច ហើយដេរដាសដោយដើមឈើតូចធំផ្សេងៗ ឬជាខាង
សមុទ្រ អាកាសក្នុងតំបន់នេះតែងតែបរិសុទ្ធស្អាតជានិច្ច ព្រោះមានព្រៃ
ព្រឹក្សាជាធម្មជាតិទទួលយកធាតុការបូនអាស៊ីតទៅប្រើជាអាហាររបស់
ដើមឈើ ហើយខ្ជាក់ឲក្សីហ្សែនចេញមក (ដើម្បីជាអាហាររបស់មនុស្ស
និងសត្វវិញ) ទើបអាកាសនៅទីនេះជាអាកាសបរិសុទ្ធស្អាតមែន ដូច្នេះ
ការស្វែងរកអាកាសល្អ ដើម្បីសេចក្ដីសុខសម្រាន្តនៃរាងកាយទើបជាការ
ខានពុំបាន ។ សូម្បីអាកាសជារបស់ខានពុំបានសម្រាប់រាងកាយ
ប្រហែលនឹងអាហារ តែអ្នកទីទាល់ក្រនៅក្នុងទីក្រុងធំចាន់មនុស្សណែន
ណាន់តាន់តាប់ ក៏ពុំមែននឹងដោះខ្លួនចេញទៅរកអាកាសបរិសុទ្ធបាន តែ
ហើយត្រូវតែក្រើនក្រតែនខ្វះទើបសមគួរ ។

# ទីពំនាក់អាស្រ័យ

ការធ្វើគេហដ្ឋានឲ្យបានទាំងធំសមរម្យនេះសូមឲ្យយល់ថាគ្រាន់តែជាគ្រឿងប្រដាប់កិត្តិយសរបស់ម្ចាស់ផ្ទះប៉ុណ្ណោះ មិនមែនឲ្យកើតសេចក្ដីសុខសប្បាយដល់រាងកាយយ៉ាងពិតប្រាកដទេ ។ ឯគេហដ្ឋាននេះមិនថាតូចឬធំទេ បើម្ចាស់ផ្ទះចេះតាក់តែងនិងរៀបចំឲ្យសមរម្យតាមសេចក្ដីត្រូវការរបស់ជីវិតហើយ គេហដ្ឋានបែបនេះនឹងនាំឲ្យបានសុខសប្បាយក្រៃលែងជាងផ្ទះធំសមរម្យ តែមិនត្រូវតាមលក្ខណៈសុខវិទ្យា ។ ឯផ្ទះដែលប្រកបដោយលក្ខណៈល្អគោងមានគុណសម្បត្តិដូចនេះ:

១.- ត្រូវធ្វើផ្ទះឲ្យឃ្លាតឆ្ងាយពីគ្នា កុំឲ្យប្រជ្រៀតគ្នាពេក ។

២.- គោងសង់ផ្ទះនៅក្នុងតំបន់ដែលមានអាកាសល្អ ប្រាសចាកគ្រឿងស្មោកគ្រោកនិងក្លិនបំពាយអាក្រក់ទាំងពួង ។

៣.- គោងមិនតាំងនៅក្នុងទីកក់ជ្រាំមានទឹកដក់ទាំងនៅ ។

៤.- គោងតាំងនៅក្នុងទីមានពន្លឺថ្ងៃ ។ល។

៥.- គោងឲ្យនៅឆ្ងាយពីរោងម៉ាស៊ីនធ្វើការឬបរិវេណមានម៉ែនក្អើននិងផ្សែងក្អើនផ្សែង ១ ។

៦.- គួរមានដើមឈើតូច - ធំនៅក្បែរបរិវេណផ្ទះដើម្បីផ្សេងអាកាសបរិសុទ្ធមកឲ្យយើង ។

៧ - គេនឹងធ្វើផ្ទះឲ្យមានលក្ខណៈ : គឺស្រឡះមានបង្អួចច្រើនខ្យល់ច្រើនដើម្បីផ្លាស់ប្តូរអាកាសចេញចូលបានស្រួល ហើយដំបូលផ្ទះគេនឹងធ្វើឲ្យបានការពារកំដៅបានផង (អ្នកទីទាល់ក្រប្រើដំបូលស្លឹកជាជាងដំបូលស័ង្កសី) ។

៨ :- គេនឹងធ្វើការសំអាតសព្វអន្លើ ។

៩ .- គេនឹងធ្វើឲ្យមាំខ្ជាប់ខ្ជួនអាចការពារភ្លៀងទឹកខ្យល់ព្យុះបាន ។

ផ្ទះដែលប្រកបដោយលក្ខណៈ ដែលពោលមកនេះ បើជាទីជនបទនៅតែក្រៅ អាចចាត់ចែងបានដោយងាយមិនបាច់ការស្រ័យកំឡាំងទ្រព្យប៉ុន្មានឡើយ ។

អ្នកទីទាល់ក្រក៏អាចចាត់ចែងបានដោយងាយមិនលំបាកឡើយ ។

## ពន្លឺរស្មីថ្ងៃអាទិត្យ

ប្រសិនបើយើងព្រោះគ្រាប់ដំណាំ ឲ្យដុះបានជាដើមមួយគូនដើម ហើយនាំយកទៅដាំកន្លែងម្លប់ ។ នៅទីណាដែលដើមឈើចំរើនលូតលាស់ឡើង យើងនឹងឃើញដើមវា ងាកបែរទៅរកពន្លឺថ្ងៃជានិច្ច ។ បើយើងយកវាទៅដាំកន្លែងដែលមិនមានពន្លឺសោះឡើយ ដើមឈើនេះនឹងស្វិតស្រពោនស្លាប់ទៅ បើទុកជាខំស្រោចទឹក ជួយដាក់ជីយ៉ាងណាក៏មិនរស់ដែរ ។ ឯពួកសត្វចិញ្ចឹមទាំងពួង បើយកវាទៅចិញ្ចឹមទុកកន្លែងដូចគ្នានេះក៏មានផលដូចគ្នាដែរ ។ ដូច្នេះទើបឃើញថាពន្លឺថ្ងៃនេះមាន

គុណប្រយោជន៍ដល់ដើមព្រឹក្សជាតិ មនុស្ស សត្វទាំងឡាយគួរទៅ ។ កំដៅដួងអាទិត្យនេះ មានឫទ្ធិអំណាចកំចាត់មេជម្ងឺពពួកខ្លះដែលប្រទុស្ស-រ៉ាយ ។ នៅទីវាលក្ដី ទីស្រែក្ដី កំដៅដួងអាទិត្យធ្វើប្រយោជន៍បាន ច្រើនជាងនៅទីក្រោមផ្ទះ ។ ដូច្នេះគេហដ្ឋានក្ដី ខ្លួនយើងក្ដី កូនចៅក្ដី ត្រូវឲ្យបានទទួលពន្លឺថ្ងៃខ្លះតាមសមគួរ ។ ស្ថានទីណាដែលស្អុះស្អាប់ ឥតពន្លឺថ្ងៃចូលដល់នោះ មិនគួរអាស្រ័យផងកោនទេ ។

## វត្ថុផ្សេងៗ ដែលនៅជុំវិញខ្លួន

វត្ថុផ្សេងៗដែលយើងនិងពោលតទៅនេះសំដៅយកតែវត្ថុដែលកើត អំពីធម្មជាតិ ទាំងរបស់ដែលមើលឃើញ ទាំងរបស់ដែលមើលមិនឃើញ ដោយឡែក ដូចជាដី, ទឹក, ខ្យល់, ភ្លៀង, កំដៅ, ត្រជាក់, ពន្លឺថ្ងៃនិងព្រឹក្ស-ជាតិ ទាំងមានគុណទាំងមានទោស មេជម្ងឺផ្សេងៗជាដើម ។ វត្ថុអស់នេះ សុំឲ្យចាំទុកក្នុងចិត្តថា ជារបស់ដែលមាននៅជុំវិញខ្លួនយើងកម្រនឹងឃ្លៀស វាងរួច ហើយត្រូវតែយើងសិក្សាឲ្យស្គាល់គុណសម្បត្តិរបស់វត្ថុនោះៗ ថា របស់ណាឲ្យគុណ របស់ណាឲ្យទោស ។ គុណនិងទោសរបស់វត្ថុនោះៗមាន កំណត់ត្រឹមណា សឹមយើងសេពគប់ និងរបស់ដែលជាមិត្តនឹងគ្នាបាន ។

រាងកាយរបស់យើងនេះមិនមែនថា នៅក្នុងសភាពមិនប្រែប្រួល ដូច្នេះជានិច្ចទៅទេ ឯវត្ថុផ្សេងៗ ដែលនៅជុំវិញខ្លួនយើងក៏តែងតែប្រែ-

ប្រួលផ្លាស់ប្តូរគ្នាជានិច្ចដែរ ឯការប្រែប្រួលរបស់កាយក្តី របស់វត្ថុផ្សេងៗ ដែលនៅជុំវិញកាយក្តី តែងមានការប្រែប្រួលទៅតាមផ្លាស់ប្តូរថែមថ្មីឡើងជានិច្ចដែរ ។

ឯវត្ថុផ្សេងៗ ដែលហោមរោមនៅជុំវិញនេះ កាលបើពោលដោយសរុបហើយ មានសេចក្តីសំខាន់ជា ២ ប្រការ គឺប្រការ ១ វត្ថុទាំងឡាយដែលកើតពីធម្មជាតិនោះជារបស់ដែលយើងចៀសពុំបាន ពុំបានសព្វគ្រប់ទេ ប្រការ ២ កាន់កាយយើងក្នុងខណៈដែលធ្វើការផ្សព្វផ្សាយឲ្យសមទៅនឹងការប្រែប្រួលនៃវត្ថុផ្សេងៗ ដែលនៅហោមរោមព្រមជាមួយគ្នា ។ កាលបើមានសេចក្តីពិតដូច្នេះក៏ល្មមយល់បានថា វត្ថុដែលនៅហោមរោមទាំងអស់នេះជារបស់ដែលមនុស្សយើងមិនគួរចៀសវាងនោះឡើយ ។ គួរតែយើងធ្វើសេចក្តីសន្និដ្ឋានទៅនឹងវត្ថុទាំងអស់នេះ ឲ្យកាន់តែច្រើនឡើងទៀត ដើម្បីឲ្យស្ថិតស្ថេរបរិកាលនៃជីវិតរបស់យើងតរៀងទៅ ។ ឯវិធីចិញ្ចឹមត្រូវនឹងវត្ថុដែលមាននៅហោមរោមជុំវិញខ្លួនយើងដូច្នេះ:

ដី - កាលណាយើងដើរចុះពីផ្ទះទៅ វត្ថុដែលទទួលរាប់រងយើងជាលំដាប់ទៅគឺផ្ទៃផែនដី ។ ដីជាវត្ថុមួយរបស់ពិភពលោកដែលប្រកបដោយវត្ថុធាតុច្រើនយ៉ាងច្រើនប្រការ វត្ថុខ្លះជាគុណ វត្ថុខ្លះជាទោសដល់ជីវិតរបស់យើង ។ ឯដីដែលមានកកស្រាំមានទឹកដក់ទាំងនៅមានក្លិនអាសោចិ៍ ឥតកំដៅ ដីបែបនេះជាដីមិនស្អាតប្រកបដោយទោស ។ (មានត)

# ឃុនសុន្ទរមេធី ញ៉ុង-សៀង ប្រែ-រៀបរៀង

## លោក ហ៊ង់-គិមសេង ពិនិត្យ

(តមកនឹងចប់)

---

ទើបខ្ញុំក្រាបទូលសូមព្រះរាជានុញ្ញាតដើម្បីវិលត្រឡប់វិញ, ទ្រង់ក៏បានអនុញ្ញាតបើកតាមបំណងខ្ញុំ ហើយទ្រង់ព្រះរាជទានរង្វាន់ខាន់ទៅជាច្រើនដល់ខ្ញុំផង ។ ខ្ញុំក៏រៀបចំដំណើរចុះនាវាក្នុងពេលនោះ ដោយបំណងថានឹងត្រឡប់មកឯស្រុកបាគដាទ ប៉ុន្តែមិនដឹងជាទោសកាលកម្មអកុសលអ្វី តែនាវាដែលខ្ញុំជិះនោះវង្វេងផ្លូវសាទក់ទៅឯណាផ្លាស់ទៅវិញ ។

លុះបើកវង្វេងផ្លូវក្នុងសមុទ្រយ៉ាងនេះ រាប់បី-បួនថ្ងៃ ស្រាប់តែទៅពេលប៉ះប្រទះនឹងព្យុះពោរសមុទ្រ ហើយត្រូវព្យុះកាំទាំងនោះក៏បែកបោកបាក់នាវារបស់យើងខ្ទេចទាំងអំណាច; ពួកអ្នកនាវាយើងខ្លះ ក៏ស៊ូប្រឹងយកដៃទន្ទឹងរក ប៉ុន្តែទប់ទល់ពុំបានត្រូវក៏ស្លាប់ទៅលង់អស់ ។ ចំណែកខាងខ្លួនខ្ញុំនិងអ្នកខ្លះទៀតដែលនៅសេសសល់ ឥតទទឹងទាស់តទ្រនឹងរក ។ ក៏ចាប់យកធ្វើជាបាវព្រាវអស់ទៅ ។

ពួកចោរទាំងឡាយនោះ ស្រាតយកសំលៀកបំពាក់របស់យើងអស់រលីងហើយក៏យកសំលៀកបំពាក់កញ្ចាស់រយ៉ៃ មកឲ្យយើងស្លៀកពាក់វិញ រួចក៏បើកទាំងសំពៅដឹកយើងទៅឯកោះមួយយ៉ាងឆ្ងាយអំពីទីនោះ; កាលទៅដល់ភ្លាម ក៏នាំយើងយកទៅលក់ឲ្យពួកអ្នកស្រុកកោះនោះឯង ។

ខ្ញុំធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃពាណិជម្នាក់ជាអ្នកមានស្តុកស្តម្ភគ្រាន់បើ គឺគេទិញខ្ញុំនាំយកទៅផ្ទះគេហើយឲ្យបរិភោគបាយឆ្អែតស្កប់ស្កល់ រួចគេយកសំលៀកបំពាក់យ៉ាងស្អាតៗ មកឲ្យខ្ញុំស្លៀកពាក់ធ្វើជាខ្ញុំកំដររបស់គេ ។ លុះតមកបានពីរ-បីថ្ងៃ, ពាណិជសួរខ្ញុំថា អ្នកឯងចេះរកស៊ីខាងរបរអ្វីខ្លះ ?" ។ ខ្ញុំឆ្លើយថា "ខ្លួនខ្ញុំនេះជាអ្នករកស៊ីជំនួញ ប៉ុន្តែត្រូវពួកចោរប្លន់ចាប់ស្រាតយកខោអាវអស់រលីង ហើយក៏នាំយកមកលក់ក្នុងទីនេះ" ។ ពាណិជសួរខ្ញុំទៀតថា "អ្នកឯងចេះបាញ់ស្នាឬទេ ?" ខ្ញុំជំរាបគាត់ថា ខ្ញុំធ្លាប់ចេះតាំងពីនៅក្មេងម៉្លេះ ប៉ុន្តែឥឡូវនេះក៏នៅចាំស្ទាត់ ល្មមបាញ់បានដែរ ។ គ្រានោះ ពាណិជបានប្រគល់ស្នាមួយហើយនឹងព្រួញមួយបំពង់មកឲ្យខ្ញុំហើយក៏ឲ្យឡើងជិះដំរីទៅជាមួយនឹងគាត់ បរចូលទៅក្នុងព្រៃឆ្ងាយអំពីទីក្រុង, ប្រហែលពីរ-បីម៉ោងទើបបានដល់ទៅទីវាលមួយដ៏ទូលាយហើយមានព្រៃព័ទ្ធជុំវិញ ។ យើងបរដំរីចូលទៅក្នុងទីនោះ ហើយពាណិជក៏ឲ្យខ្ញុំចុះត្រង់កន្លែងគួរសម រួចហើយ គាត់ចង្អុលបង្ហាញដើមឈើមួយដើមយ៉ាងធំហើយនិយាយថា

"ចូរឯងឡើងដើមឈើនេះ   អង្គុយឃ្លាំចាំបាញ់ដំរីដែលដើរទៅមកត្រង់ចន្លោះនេះ ព្រោះក្នុងព្រៃនេះឯងសម្បូរដំរីណាស់, កាលបើឯងបាញ់ត្រូវកដួលស្លាប់ហើយ   ចូរត្រឡប់ទៅឲ្យដំណឹងយើងជាប្រញាប់កុំខាន" ។ លុះនិយាយពន្យល់ខ្ញុំយ៉ាងនេះរួចហើយ   ទើបគាត់ចុកសៀងឲ្យខ្ញុំជាច្រើនល្មមបរិភោគបានយូរថ្ងៃទៅមុខ   រួចគាត់ត្រឡប់ទៅកាន់ទីក្រុងវិញទៅ;ចំណែកខាងខ្ញុំៗ ឡើងទៅពួនសម្ងំលើដើមឈើ   ឃ្លាំចាំមើលពេញមួយយប់នោះ  ឥតបានដេកសោះ ។

ក្នុងពេលរាត្រីនោះ  ខ្ញុំឥតបានឃើញដំរីមួយទេ; លុះដល់ព្រលឹមឡើងអរុណរះព្រាងៗ ស្រាប់តែលេចដំរីមួយហ្វូងធំដើរមកត្រង់ទីនោះ, ខ្ញុំក៏តាំងបាញ់ជាច្រើនព្រួញ   ហើយដល់ទៅក្នុងទីបំផុត   ឃើញដំរីមួយដួលដេកបញ្ច្រាងលើផែនដី ។ ដំរីឯទៀតៗផ្អើលរត់បោលចូលទៅក្នុងព្រៃអស់រលីង  ទើបខ្ញុំមីមាចុះពីដើមឈើហើយត្រឡប់ទៅកាន់ទីក្រុងវិញដើម្បីឲ្យដំណឹងដល់ចៅហ្វាយខ្ញុំ ។ ដោយសេចក្ដីពេញចិត្តនឹងដំណឹងនេះ   ចៅហ្វាយខ្ញុំក៏តាំងជប់លៀងខ្ញុំឲ្យស៊ីផឹកយ៉ាងសប្បាយ ហើយគាត់សរសើរពីការប៉ិនប្រសប់របស់ខ្ញុំ ។ រួចហើយយើងទៅឯចន្លោះនោះវិញទាំងពីរនាក់  ហើយក៏ជីករណ្ដៅយ៉ាងធំកប់ខ្មោចដំរីដែលខ្ញុំបាញ់ស្លាប់នោះ ។ ចៅហ្វាយខ្ញុំប្រាប់ខ្ញុំថា  កាលណាដំរីនេះស្អុយរលួយអស់សាច់

ឈាមហើយ គាត់នឹងមកគាស់យកគ្រឿងចេញទាំងកញ្ចក់ទៅលក់ ៗ កាលធ្វើកិច្ចនេះរួចហើយ គាត់វិលត្រឡប់ទៅកាន់ទីក្រុងវិញ ៗ

ខ្ញុំក៏នៅឃ្លាំចាំបាញ់តទៅទៀតរាប់ពីរខែ ហើយខ្ញុំបាញ់បានដំរីជាច្រើនទៀតរាល់ៗថ្ងៃ ខ្ញុំមិនពួនសម្ងំឃ្លាំចាំមើលតែលើដើមឈើដដែលៗទេ, ជួនកាលខ្ញុំឃ្លាំចាំមើលលើដើមខាងនេះ ជួនកាលលើដើមខាងនោះ, ចេះតែផ្លាស់ប្តូរយ៉ាងនេះជាដរាប ៗ ក្នុងថ្ងៃមួយ ពេលព្រឹកខ្ញុំឃើញដំរីមួយហ្វូងធំ ដើរសំដៅចូលមកជិតដើមឈើដែលខ្ញុំពួនសម្ងំនោះហើយ បន្ទូរសូរសំឡេងខ្ទរខ្ទារយ៉ាងសម្បើម ឮលាន់រំពងពេញទាំងព្រៃ ហើយសូរសន្ធឹកជើងទន្ទ្រំ ហាក់ដូចជាកក្រើកផែនសៅញ្ជួកស្រុតទាំងផែនដី ៗ វាចូលមកជិតពោមពេមឡោមព័ទ្ធជុំវិញដើមឈើខ្ញុំ ហើយទំលាក់ប្រមោយយោលចុះយោលឡើងងើយសំឡឹងមើលមករកខ្ញុំមិនដាក់ភ្នែកសោះ ៗ ចំណែកខាងខ្ញុំខំប្រឹងពួនសម្ងំឧបមែងឈើធ្វើកំប្រោន ៗ ព្រលឹងនៅចុងសក់ញ័ររន្ធត់ជាងគេនញាក់ទៅទៀត ទាំងស្នាទីងព្រួញក៏របូតធ្លាក់ពីដៃអស់រលីង ៗ

ដំរីទាំងឡាយនោះមិនមែនគ្រាន់តែធ្វើបំភ័យខ្ញុំទទេៗប៉ុណ្ណោះឡើយ, លុះរាល់ឈរសំឡឹងមើលខ្ញុំមួយស្របក់យ៉ាងនេះហើយ ស្រាប់តែដំរីមួយធំដែលជាមេហ្វូង យកប្រមោយមកចាប់ក្រសោបរួបគល់ឈើហើយទាញដករំលំដោយកំឡាំងយ៉ាងខ្លាំងអស្ចារ្យ ៗ ដើមឈើនោះក៏រលើង

ចាំងគល់ រលំព្រួស ត្រាំងចាំងខ្លួនខ្ញុំក៏ធ្លាក់មកជាមួយនឹងដើមឈើ ឥតមានសេចក្តីសង្ឃឹមថានឹងបានរស់តទៅទៀតឡើយ ប៉ុន្តែដំរីនោះស្ទុះមកជិតហើយលូកប្រមោយត្រកងខ្ញុំលើកដាក់ទៅលើខ្នងវា ។ ខ្ញុំអង្គុយលើខ្នងដំរី ស្តាយចំពន់ព្រួញដាប់នឹងស្មាបាក់ស្មារតីស្ទើរឈឺដូចជាមនុស្សស្លាប់ រួចហើយវានាំគ្នាដើរចេញអំពីទីនោះទៅទាំងហ្វូងនាំខ្ញុំទៅរហូតដល់ព្រៃមួយ ក៏ដាក់ខ្ញុំចោលនៅនឹងដីហើយវានាំហ្វូងវាចៀសចេញអំពីទីនោះបាត់ទៅ ។ ខ្ញុំនៅដេកស្ងួតស្ងៀមលើផែនដីស្រពិចស្រពិលហាក់ដូចជាដេកលក់ ប៉ុន្តែកាលខ្ញុំបើកភ្នែកឡើងឥតឃើញដំរីមួយសោះហើយក៏ក្រោកឡើងអង្គុយមើលទៅឆ្វេងមើលស្តាំ ស្រាប់តែឃើញខ្លួនឯងនៅលើទួលខ្ពស់មួយ មានទំហំទូលាយគួរសមហើយឃើញតែធ្អឹងនឹងភ្លុកដំរីដេរដាសពាសពេញក្នុងទួលនោះឯង ។ ដំណើរនេះនាំបណ្តាលឲ្យខ្ញុំមានសេចក្តីភ្ញៀងឆ្ងល់ពន់ពេក; ប៉ុន្តែដល់ពិចារណាមើលសព្វទៅ ខ្ញុំយល់ឃើញថា ទីនោះជាព្រៃស្មសាន (កន្លែងពោលខ្មោច) នៃពួកដំរី ហើយដែលវានាំខ្ញុំយកទៅដាក់ត្រង់កន្លែងនោះ គឺវាមានបំណងចង់បង្ហាញគំនរភ្លុកដំរីដល់ខ្ញុំ ដើម្បីកុំឲ្យខ្ញុំបៀតបៀនដល់ពួកដំរីតទៅទៀត ឲ្យយកតែភ្លុកដំរីស្រាប់ៗ លើទួលតែប៉ុណ្ណោះក៏ល្មមហើយ ។ ខ្ញុំមិនឈប់ចន្លំលើទួលខ្ពស់នោះទេ, ខ្ញុំវិលត្រឡប់មកតាមទីក្រុងយ៉ាងប្រញាប់ប្រញាល់; លុះដើរពេញមួយថ្ងៃមួយយប់ ទើបបានមកដល់ផ្ទះ

ចៅហ្វាយខ្ញុំ ៗ កាលធ្វើដំណើរតាមផ្លូវ ខ្ញុំឥតប្រទះឃើញដំរីមួយសោះ រឿងនេះ អាចឲ្យខ្ញុំយល់បានថាពួកដំរីនាំគ្នាចូលទៅក្នុងព្រៃឆ្ងាយអំពីផ្លូវ ដើម្បីបើកឱកាសឲ្យខ្ញុំដើរទៅមុខបានដោយស្រួលកុំឲ្យកើតភ័យ ៗ.

កូនក្រមុំដែលចៅហ្វាយនាយបានឃើញខ្ញុំទៅដល់ហើយ គាត់និយាយដោយសេចក្ដីត្រេកអរមកកាន់ខ្ញុំថា "សិទ្ធបាទ! ខ្ញុំមានសេចក្ដីព្រួយបារម្ភខ្លាំងណាស់ ដោយបាត់អ្នកយូរពេក មិនឃើញត្រឡប់មកសោះ, ខ្ញុំបានតាមទៅរកក្នុងព្រៃឃើញតែដើមឈើទើបនឹងរលំថ្មីៗ ហើយឃើញតាំងស្នាមនិងព្រៃញជ្រះនៅក្បែរទីនោះផង . ខ្ញុំក៏អស់សង្ឃឹមលែងតាមរកអ្នកតទៅទៀត ដោយយល់ឃើញថា មុខជាដំរីជាន់សម្លាប់អ្នកបាត់ទៅហើយ ឥឡូវនេះស្រាប់តែលេចមុខអ្នកត្រឡប់មកវិញ ដោយសុខសួស្ដី ហេតុនេះ ចូរអ្នកសារសព្វរឿងរ៉ាវប្រាប់ខ្ញុំកុំខាន ដោយភ័ព្វសំណាងដូចម្ដេច បានជាអ្នករស់រួចជីវិតមកវិញ?" ៗ ខ្ញុំក៏បាននិយាយរឿងនោះ ជំរាបចៅហ្វាយនាយ តាមហូរហែសព្វគ្រប់; លុះថ្ងៃស្អែកឡើង ទើបយើងជិះដំរីចរទៅឯចន្លោះទួលខ្ពស់នោះទាំងពីរនាក់ កាលបានឃើញគំនរធ្អឹងនិងភ្លុកដំរីដេរដាសពាសពេញមិនអាចនឹងគណនាត្រាតប់បានដូចពាក្យដែលខ្ញុំនិយាយជូនចោះ :ចៅហ្វាយខ្ញុំក៏មានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ៗ យើងបានផ្ទុកភ្លុកដំរីជាច្រើនលើខ្នងដំរីរបស់យើងហើយវិលត្រឡប់មកកាន់ទីក្រុងវិញ: គ្រាដែល

បានមកដល់ផ្ទះហើយ ចៅហ្វាយខ្ញុំលោកនិយាយថា "ប្អូន! ខ្ញុំមិនត្រូវការទុកអ្នកជាប្រើប្រាស់ដូចជាខ្ញុំកំដរតទៅទៀតទេ ព្រោះអ្នកបានបង្ហាញកំណាប់ជាទីពេញចិត្តដែលនាំឲ្យខ្ញុំក្លាយខ្លួនទៅជាអ្នកមានទ្រព្យសម្បត្តិបាន; សូមឲ្យព្រះជាម្ចាស់ជួយចំរុងចំរើនអ្នក ដោយភោគសម្បទនិងសិរីសួស្តីគ្រប់យ៉ាង! ខ្ញុំសូមតាំងសច្ចាប្រណិធានចំពោះមុខព្រះថាខ្ញុំនឹងលែងអ្នកឲ្យរួចជាអ្នកជាក្នុងកាលឥឡូវនេះ; កាលមុនដំបូង រឿងបរបាញ់ដំរីនោះខ្ញុំបានលាក់បិទបាំងមិនប្រាប់អ្នកឲ្យដឹងសព្វគ្រប់ទេ ក្រែងលោអ្នកមានសេចក្តីភិតភ័យ គឺកាលពីមុនមករាល់ៗឆ្នាំ ពួកដំរីក្នុងព្រៃនោះតែងជាន់សម្លាប់បាវព្រាវរបស់ខ្ញុំជាច្រើនរូប ដែលខ្ញុំបានប្រើទៅឲ្យឃ្លាំចាំបាញ់យកភ្លុក, ទោះបីខ្ញុំប្រាប់ពន្យល់ៗ ឲ្យគេការពារខ្លួនយ៉ាងដូចម្តេចក៏ស្ទុះមិនរួចអំពីសេចក្តីព្យាបាទរបស់វាដែរ, បើមិនចាប់ក៏យូរគង់តែត្រូវអន្តរាយខ្លួនពុំខាន, ឃើញមានកំពូលសំណាងតែរូបអ្នកឯងមួយប៉ុណ្ណោះ ដោយសារព្រះជាអម្ចាស់ទ្រង់ត្រូវការស្រឡាញ់អ្នកជាងគេនៅក្នុងឋានកណ្តាលនេះ ទ្រង់ចេះតែជួយអ្នកបានចំពោះកិច្ចកុសលដែលអ្នកត្រូវធ្វើ; អ្នកឯងឈ្មោះថាបានជួយជ្រោមជ្រែងខ្ញុំឲ្យបានចំរុងចំរើនជាទីបំផុត ព្រោះតាំងអំពីកាលដែលខ្ញុំចាប់រកស៊ីរបរនេះមក ស្លាប់អស់ខ្ញុំកំដរជាច្រើនណាស់ហើយ ខ្ញុំមិនដែលបានភ្លុកដំរីច្រើនដល់ម្ល៉េះទេ; ម្យ៉ាងទៀត ទាំងទីក្រុងរបស់យើង ក៏ឈ្មោះថាបានចំរើនរុងរឿង

ដោយសារអ្នកកេឃើញកំណាប់ ឬអ្នកជឿជាក់ប្រាកដថា ខ្ញុំមិនមែនលែងអ្នកឲ្យរួចជាអ្នកជា ដោយគ្រាន់តែបើកឲ្យរួចតែខ្លួនទទេនោះឡើយ ខ្ញុំនឹងបន្ថែមទ្រព្យសម្បត្តិជាច្រើនដើម្បីជារង្វាន់ដល់អ្នកថែមទៀតផង" ។

កាលគាត់និយាយពាក្យផ្អែមល្ហែមដូច្នេះហើយ ខ្ញុំក៏ពោលតបទៅវិញថា "លោក! សូមឲ្យព្រះជួយអភិបាលរក្សាលោកឲ្យបានសេចក្ដីចំរុងចំរើន! ដោយសារខ្ញុំបាទមានគុណចំណាប់ត្រឹមជួយចំរុងចំរើនលោកព្រមទាំងរំដោះស្រង់លោកឲ្យបានចំរើននោះ ខ្ញុំបាទមិនចង់បានរង្វាន់អ្វីជាទេ សូមឲ្យតែលោកអនុញ្ញាតបើកច្បាប់ឲ្យខ្ញុំបានវិលត្រឡប់ទៅស្រុកវិញតែប៉ុណ្ណោះ ក៏ទុកជាជារង្វាន់ដ៏ខ្ពង់ខ្ពស់ណាស់ទៅហើយ" ។ គាត់ឆ្លើយឡើងភ្លាមថា "សិន្ទបាទ, មិនជាការលំបាកសោះទេ ប៉ុន្តែត្រូវបង្អង់ចាំបន្តិចទៀតសិន ទម្រាំតែដល់រដូវមានខ្យល់ជំនោរយ៉ាងខ្លាំង ដែលអាចបក់នាំសំពៅឲ្យចូលមកកាន់ទីនេះបាន ដើម្បីនឹងផុតភ្លុកដំរីទៅលក់ដូរឯប្រទេសក្រៅនោះ ខ្ញុំនឹងបញ្ជូនអ្នកឲ្យទៅជាមួយនឹងសំពៅនោះហើយនឹងឲ្យអីវ៉ាន់ស្តុកការផ្សេងៗ ជាស្បៀងតាមផ្លូវផង" ។ ខ្ញុំមានសេចក្ដីអរគុណជាច្រើន ដោយគាត់បានបើកលែងខ្ញុំឲ្យរួចជាអ្នកជានឹង ដោយសារគាត់មានអធ្យាស្រ័យល្អចំពោះរូបខ្ញុំ ។ ខ្ញុំនៅជាសុខសប្បាយក្នុងផ្ទះគាត់ រង់ចាំទម្រាំតែដល់រដូវនោះឯង; ក្នុងគ្រាដែលនាវាមិនទាន់មកដល់ យើងទៅដឹកជញ្ជូនភ្លុកដំរីអំពីទីទួលខ្ពស់ជាច្រើនលើកច្រើន

ត្រាយកមកបំពេញឃ្លាំងគាត់ឲ្យពេញបរិបូណ៌ ។ រឿងនេះមិនជាស្ងាត់កំបាំងទេ លេចឮដល់អ្នកជំនួញទាំងអស់ក្នុងទីក្រុងនោះ គេក៏នាំគ្នាទៅដឹកជញ្ជូនយកមកលក់ដូរតាមចំណែករៀងៗខ្លួន ។

មិនយូរប៉ុន្មាន ឃើញសំពៅជាច្រើនចូលមកចតនៅទីក្រុងនោះ ហើយចៅហ្វាយខ្ញុំក៏ជ្រើសរើសរកសំពៅដែលស្អាតបាតមាំមួនល្មមនឹងឲ្យខ្ញុំទៅដោយសារផងបាន រួចគាត់ឲ្យគេផ្ទុកចំណែកភ្លុកពាក់កណ្ដាលក្នុងសំពៅនោះ ដើម្បីជារង្វាន់ដល់ខ្ញុំ ព្រមទាំងកំស្តុការស្បៀងអាហារផ្សេងៗទៀតជាច្រើនសម្រាប់បរិភោគតាមផ្លូវ ហើយគាត់បានឲ្យគ្រឿងបណ្ណាការយ៉ាងមានដំឡៃថ្លៃទៀតផង, ខ្ញុំសំដែងសេចក្ដីអរគុណច្រើនចំពោះចៅហ្វាយខ្ញុំហើយក៏ជំរាបលាគាត់ចុះសំពៅ រួចគេបើកក្ដោងចេញទៅអំពីទីនោះ, ចំណែកខាងខ្លួនខ្ញុំចេះតែមានគំនិតគិតគូរចំពោះខ្លួនឯងជានិច្ច ព្រោះរឿងដែលបណ្ដាលឲ្យខ្ញុំបានរួចជាអ្នកជា នេះប្លែកខុសពីគេឆ្ងាយណាស់ ។

យើងឈប់ចតសំពៅហូរហែតាមកោះជាច្រើន ដើម្បីទិញដូរគ្រឿងបរិភោគផ្សេងៗ ។ សំពៅយើងបានទៅដល់កំពង់ផែមួយក្នុងប្រទេសឥណ្ឌាដែលជាទីមានដីគោក (មិនមែនជាកោះ) យើងក៏ឈប់ចតសំពៅនៅទីផែនោះ ។ ចំណែកខាងខ្ញុំ, ដើម្បីចៀសវាងអំពីគ្រោះថ្នាក់តាមផ្លូវទឹកហេតុមកដល់ក្រុងបាល់ស៊ូរ៉ា, ខ្ញុំលែងជិះសំពៅតទៅទៀតហើយ ខ្ញុំឲ្យគេជញ្ជូនភ្លុកដំរីរបស់ខ្ញុំទៅដាក់លើគោក ដោយបំណងថា

ទីនធ្វើដំណើរទៅតាមផ្លូវគោកម្ដង ៗ ខ្ញុំបានចំណាយក្នុងនោះលក់ដូរ បានប្រាក់យ៉ាងច្រើន ហើយទិញរបស់ថ្មីប្លែកៗ យ៉ាងពិសេសជាច្រើនទៀតក្នុងទីនោះ ដើម្បីជាគ្រឿងបណ្ណាការកំដរដៃយកទៅស្រុកខ្ញុំ ។ កាលខ្ញុំរកបានជំនិះខាងជើងគោកសម្រាប់ផ្ទុកអីវ៉ាន់បានស្រេចហើយ ខ្ញុំបានទៅរួបរួមចូលដៃជាមួយនឹងពួកសត្ថពាណិជ[១] ជាដើមដែលមានដំណើរត្រូវគ្នា, ខ្ញុំធ្វើដំណើរតាមផ្លូវអស់កាលជាយូរជាមួយនឹងពួកពាណិជទាំងនោះ ហើយខ្ញុំក៏មានសេចក្ដីនឿយហត់ខ្លាំង ប៉ុន្តែខ្ញុំខំអត់ទ្រាំបាន ដោយខ្ញុំរំពឹងគិតឃើញថា ដំណើរតាមផ្លូវគោកបែបនេះជាការស្រួលម្យ៉ាង ឥតមានសេចក្ដីភិតភ័យអំពីខ្យល់ព្យុះ អំពីពួកមនុស្សជាសត្រូវចាំស្ទាក់ប្លន់, អំពីសត្វអាសិរពិសនឹងអំពីអន្តរាយផ្សេងៗ ទៀតដូចកាលដែលខ្ញុំបានប្រទះក្នុងលើកមុនៗ នោះឡើយ ។ ដល់ទៅទីបំផុតខ្ញុំបានមកដល់ក្រុងបាគដាទនេះដោយសេចក្ដីសុខសប្បាយ ។ មុនដំបូងខ្ញុំចូលទៅថ្វាយបង្គំគាល់ព្រះបាទកាលិហ្វ៍ ដើម្បីក្រាបទូលអំពីទុក្ខកិច្ចដែលខ្ញុំបានទទួលភារៈនោះឯង ។ ព្រះរាជាអង្គនេះមានបន្ទូលនឹងខ្ញុំថា ទ្រង់មានសេចក្ដីព្រួយព្រះរាជហឫទ័យខ្លាំងព្រោះបាត់ខ្ញុំយូរពេក ប៉ុន្តែទ្រង់នៅតែមានសេចក្ដីសង្ឃឹមថា ទោះបីដូចម្ដេច ក៏ព្រះមិនលះបង់ចោលបណ្ដោយឲ្យខ្ញុំស្លាប់អសារឥតការដែរ ; កាលទ្រង់ជ្រាបរឿងដំណើររឿង

១ ឈ្មួញទេះ ។

ប្លែកៗ គួរអស្ចារ្យដទៃទៀតដែលខ្ញុំបានក្រាបទូលតាមហូរហែនោះហើយ ទ្រង់មានព្រះបន្ទូលឲ្យស្មៀនម្នាក់សរសេរតែរឿងទាំងនោះ ដោយអក្សរមាស ដើម្បីរក្សាទុកឲ្យមានគង់ជំនាន់វង្សរបស់ព្រះអង្គ ។ ទ្រង់បានព្រះរាជទានរង្វាន់ជាច្រើនដល់ខ្ញុំទៀត ខ្ញុំក៏ថ្វាយបង្គំលាថយខ្លួនទៅកាន់គេហដ្ឋានរបស់ខ្លួន រួចហើយខ្ញុំយកទ្រព្យសម្បត្តិដែលបានមកទាំងនោះមកចិញ្ចឹមក្រុមញាតិ, ទាំងបងប្អូននឹងមិត្តសំឡាញ់ទាំងឡាយ ។

សិន្ទបាទ បញ្ចប់រឿងដំណើរទី ៧ ដែលជាដំណើរក្រោយបង្អស់ត្រឹមប៉ុណ្ណោះឯង ហើយក៏មានវាចាទៅកាន់ហិន្ទបាទថា "នែហិន្ទបាទសំឡាញ់! មនុស្សដែលបានទទួលសេចក្ដីទុក្ខទោសគ្រោះថ្នាក់ដូចយ៉ាងខ្លួនខ្ញុំនេះ អ្នកធ្លាប់បានចួបប្រទះឬក៏ធ្លាប់បានឮគេនិយាយដែរឬអ្វី; លុះបានរួចអំពីគ្រោះថ្នាក់ទាំងនោះហើយ ខ្ញុំបានមកតាំងខ្លួនជាអ្នកមានស្ដុកស្ដម្ភស៊ីផឹកកំសាន្តសប្បាយឥតមានអំពល់ព្រួយនឹងអ្វីយ៉ាងនេះ គេថាការមិនសមរម្យឬដូចម្ដេច ? ហិន្ទបាទចូលទៅជិតហើយឆ្លើយថា "លោកម្ចាស់ថ្លៃអើយ! ខ្ញុំបាទមិនដែលឃើញមិនដែលឮទេ មានតែលោកមួយប៉ុណ្ណោះដែលបានចួបប្រទះនឹងសេចក្ដីអន្តរាយយ៉ាងសម្បើមអស្ចារ្យ, ឯសេចក្ដីទុក្ខលំបាករបស់ខ្ញុំបាទ យកទៅប្រៀបផ្ទឹមនឹងសេចក្ដីទុក្ខវេទនារបស់លោកពុំបានឡើយ. លោកមិនមែនចិញ្ចឹមជីវិតបានដោយសាន្តត្រាណតែម្យ៉ាងប៉ុណ្ណោះទេ គឺមានទាំងបែបកាលលំបាកជាមនុស្សល្មមគួរសមដល់

ទ្រព្យសម្បត្តិទាំងអស់ទៀតផង ព្រោះលោកមានអធ្យាស្រ័យធំទូលាយ ចែកចាយធនធានជាទានដល់សាធារណជនយ៉ាងនេះ ។ សូមឲ្យលោកបានសមប្រកបដោយអាយុយឺនយូរសប្បាយរីករាយដរាបរៀងរាបទៅទល់គាន់ទីអវសាននៃអាយុសង្ខាររបស់លោក ។

សិទ្ធបាដឲ្យគេយកប្រាក់មួយរយកហាបណៈមកឲ្យទៀត ហើយទទួលយកហិន្ទុបាដធ្វើជាប៉ុយមិត្រ លើកឲ្យមានមុខមាត់ស្មើគ្នានឹងមិត្រសំឡាញ់ឯទៀតៗដែរ រួចប្រាប់ហិន្ទុបាដឲ្យលះបង់ថ្នាក់ជាគូលីស៊ីឈ្នួលវែកតុននោះចោលចេញ ហើយឲ្យមកបំរើគោតកំសាន្តសប្បាយរួមរួមជាមួយគ្នាតទៅរហូតដល់អស់ជីវិតរៀងៗខ្លួន ។

ចប់ភាគទី ១៣ នៃប៉ុណ្ណៈ ។

សូមអញ្ជើញអស់លោក - អ្នកមើលរឿងរ៉ាវប្លែកៗ ក្នុងភាគទី ១៤ តទៅទៀតកុំខាន ។

យុវចរិយាកថា

# ពោលអំពីការប្រព្រឹត្តិរបស់យុវជន

ព្រះគ្រូបញ្ញាលិខិត កៅ-សឹម គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់
ថ្នាក់ទី ៣ (ក្រុងភ្នំពេញ) រៀបរៀង

---

## អំពីការសង្គ្រោះមហាជន

កើតមកជាមនុស្សក្នុងសាកលលោក ត្រូវជាអ្នកពិចារណា ស្គាល់ប្រមាណក្នុងការសង្គ្រោះមហាជននោះៗ គួរស្គាល់តាមលំដាប់ គឺស្គាល់ថា: អ្នកនេះស្មើនឹងអ្នកនោះ ជននេះមានគុណស្មើនឹងជននោះ ហើយស្រះស្រួលទទួលបុរសនោះៗ តាមវិធីដែលត្រូវទទួល ៗ

ដែលថាស្គាល់តាមលំដាប់នោះ គឺស្គាល់ប្រាកដថា: បុរសពួកនេះជាន់ខ្ពស់ ពួកនេះជាន់កណ្ដាល ពួកនេះជាន់ទាប ព្រមទាំងគុណវិសេសនឹងសេចក្ដីសុខទុក្ខបុរសនោះៗ ថា: បុរសនេះគួរទទួលបដិសណ្ឋារៈនឹងការសង្គ្រោះបែបនេះៗ នឹងគ្រឿងសក្ការៈប៉ុណ្ណេះៗ លុះស្គាល់ដូច្នេះហើយ ក៏បានធ្វើប្រយោជន៍ប្លែកៗគ្នា ជម្រើទៅតាមគុណវិសេសនឹងសេចក្ដីសុខទុក្ខរបស់បុរសជននោះៗ ឬក៏ប្រាថ្នាសេចក្ដីប៉ុនប៉ងធ្វើឲ្យបរិបូណ៌ដល់ជនទាំងនោះថា: "សូមកុំឲ្យសាបសូន្យចាកសេចក្ដីសុខសប្បាយឡើយ សូមឲ្យបានប្រកបដោយសទ្ធានឹងគុណគឺសេចក្ដីល្អគ្រប់ប្រការ នឹងទ្រព្យ

សម្បត្តិគូរប្រពន្ធ ញាតិមិត្រ ផៅពង្ស ពណ៌សម្បុរកាយឲ្យមាំមួន កុំឲ្យមានសេចក្ដីចង្រៃពួយពាំងពួងកើតឡើងបាន បើទុកណាជាកើតឡើងហើយ ក៏សូមឲ្យវិនាសបាត់បង់ទៅវិញ" ។

កាលបើស្គាល់មិនខុសដូច្នេះ បានឈ្មោះថាជាអ្នកស្គាល់អំពើដែលខ្លួនត្រូវធ្វើទៅតាមលំដាប់មិនឲ្យខុសទំនង ដែលជាហេតុមិនឲ្យអ្នកផងគេនិន្ទាបានឡើយ ពោះបើធ្វើការអ្វីៗ ក៏នឹងបានសេចក្ដីសុខចំរើនគ្រប់ប្រការជាប្រាកដ ដូចជាព្រះសម្ពុទ្ធជាម្ចាស់នៃយើងព្រះអង្គជាបុគ្គលស្គាល់ប្រមាណក្នុងការដែលសង្គ្រោះមនុស្សសត្វកំពុងមានសេចក្ដីទុក្ខវេទនាក្នុងខ្លួន ទ្រង់ព្រះមេត្តាជួយសង្គ្រោះសត្វនោះៗ ឲ្យបានរួចចាកសេចក្ដីទុក្ខហើយ ឲ្យប្រកបនូវសេចក្ដីសុខចំរើន មានសេចក្ដីដំណាលថា:

សម័យនោះឯង ភិក្ខុ ១ រូបមានរោគឈឺពោះ ដេកត្រាំនៅលើមូត្រនិងករីសរបស់ខ្លួន ។ គ្រានោះ ព្រះដ៏មានព្រះភាគមានព្រះអានន្ទជាបច្ឆា-សមណៈទ្រង់ពុទ្ធដំណើរទៅកាន់សេនាសនចារិក (រោងជម្ងឺ) ហើយចូលទៅទីលំនៅភិក្ខុនោះ ទ្រង់ទតឃើញហើយត្រាស់សួរថា:

ម្នាលភិក្ខុ អ្នកមានរោគអ្វី?

មានភិក្ខុអ្នកបំរើដែរឬ?

ចុះពួកភិក្ខុហេតុអ្វីក៏មិនបំរើអ្នក?

ភិក្ខុនោះក្រាបទូលថា ខ្ញុំព្រះអង្គមានរោគឈឺពោះ សូមទ្រង់មេត្តាប្រោសគ្មានអ្នកណាបំរើទេ ព្រោះខ្ញុំព្រះអង្គមិនដែលបានធ្វើ (ឧបការៈ) ដល់ពួកភិក្ខុសោះ ៗ លំដាប់នោះព្រះសម្ពុទ្ធទ្រង់ត្រាស់ប្រើអានន្ទឲ្យនាំយកទឹកមកឲ្យភិក្ខុនោះងូត ទ្រង់ស្រោចទឹក ព្រះអានន្ទដុសលាង រួចទ្រង់ចាប់ខាងក្បាល ព្រះអានន្ទចាប់ខាងជើង សែងឡើងយកទៅដាក់ឲ្យដេកលើគ្រែតូចមួយ ហើយមានព្រះពុទ្ធត្រាស់ថា: ម្នាលភិក្ខុទាំងឡាយអ្នកពល់គ្នាគ្មានមាតាបិតាទេ បានអ្នកណាបំរើអ្នក បើអ្នកទាំងឡាយមិនបំរើគ្នានឹងគ្នាហើយ តើបានអ្នកណានឹងបំរើវិញ ទើបទ្រង់ត្រាស់ថា: បុគ្គលបំរើជម្ងឺប្រកបដោយអង្គ ៥ ទើបគួរបំរើបាន, បុគ្គលមិនប្រកបដោយអង្គ ៥ មិនគួរនឹងបំរើជម្ងឺ; បុគ្គលមានជម្ងឺប្រកបដោយអង្គ ៥ លំបាកគេបំរើ, បុគ្គលមានជម្ងឺប្រកបដោយអង្គ ៥ ងាយគេបំរើ កុំកន្លងអង្គនីមួយៗ ទាំងមានសំដែងតទៅនេះ ៗ

## អង្គបុគ្គលអ្នកបម្រើជម្ងឺ ៥ យ៉ាង

១- បដិពល ជាមនុស្សប៉ិនប្រសប់វាត់វែងថ្នាំ (ផ្សំថ្នាំ)

២- សប្បាយាសប្បាយ ស្គាល់ហេតុសប្បាយនិងមិនសប្បាយ

៣- អសប្បាយ នាំរបស់ដែលមិនសប្បាយចេញទៅ នាំរបស់ដែលសប្បាយចូលមក

៤- មេត្តចិត្ត មានចិត្តប្រកបដោយមេត្តា មិនប្រាថ្នាអាមិស ហើយបម្រើជម្ងឺ មិនខ្ពើមរអើមក្នុងការនាំចេញនូវឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី កំអួតក្តី

៥- បណ្ឌិត ចេះពន្យល់អ្នកមានជម្ងឺឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យរីករាយដោយធម្មកថា (របស់ខ្លួន) សព្វៗកាល ទើបគួរនឹងបម្រើមនុស្សដែលមានជម្ងឺបាន ។

## អង្គបុគ្គលអ្នកមិនគួរបម្រើជម្ងឺ ៥ យ៉ាង

១- ន បណ្ឌិត មិនចេះប្រសប់ចាត់ចែងថ្នាំ (ផ្សំថ្នាំ)

២- សប្បាយាសប្បាយ មិនស្គាល់ហេតុសប្បាយនឹងមិនសប្បាយ

៣- អសប្បាយ នាំរបស់ដែលមិនសប្បាយចូលទៅ នាំរបស់ដែលសប្បាយចេញមក

៤- អាមិសន្តរ បម្រើអ្នកជម្ងឺចង់បានតែអាមិស ឥតមានចិត្តមេត្តា មានតែខ្ពើមរអើមនឹងការនាំចេញនូវឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី កំអួតក្តី

៥- ន បណ្ឌិត មិនចេះពន្យល់អ្នកមានជម្ងឺឲ្យឃើញច្បាស់ ឲ្យកាន់យកតាមឲ្យរីករាយដោយធម្មកថាសព្វៗកាល មិនគួរនឹងបម្រើមនុស្សជម្ងឺ ។

## អង្គអ្នកជម្ងឺ ៥ យ៉ាងលំបាកគេបម្រើ

១– អសប្បាយការី មិនបេះធ្វើខ្លួនឲ្យសប្បាយ

២– សប្បាយមត្តំ មិនដឹងប្រមាណក្នុងការសប្បាយ

៣– ន បដិសេវិតា មិនខំខ្នះខ្នែងប្រើថ្នាំ (ផឹកថ្នាំ)

៤– នាវិកត្តា មិនប្រាប់អាពាធដែលចំរើនថាចំរើន គឺ ដែលធូរថយថាធូរថយ ដែលនៅនឹងដែលថានៅនឹងដែលគង់ ឲ្យប្រាប់តាមពិតដល់អ្នកបម្រើជម្ងឺ ដែលជាអ្នកចង់ឲ្យសះជា

៥– អនធិវាសកជាតិកា មិនអត់សង្កត់ខ្លួនក្នុងវេទនាដ៏រឹងក្លាផ្សាក្តៅ ដែលកើតឡើងក្នុងប្រជុំនៃសរីរៈ ។

## អង្គអ្នកជម្ងឺ ៥ យ៉ាងងាយគេបម្រើ

១– សប្បាយការី បេះធ្វើខ្លួនឲ្យសប្បាយ

២– សប្បាយមត្តំ ដឹងប្រមាណក្នុងការសប្បាយ

៣- បដិសេវិតា ខំខ្នះខ្នែងប្រើថ្នាំ (ផឹកថ្នាំ)

៤ - អាវិកត្តា ប្រាប់ជម្ងឺដែលចំរើនឡើង ថាចំរើនឡើងដែលធូរថយថាធូរថយ ដែលនៅនឹងដែលថានៅនឹងដែលឲ្យប្រាប់ណាស់ដល់អ្នកបម្រើ ដែលជាអ្នកចង់ឲ្យសះជា

៥ - អធិភសក្កជាតិកា ជាអ្នកអត់ទ្រាំទ្រទុកវេទនា ដ៏រឹងក្លាផ្សាក្តៅ ដែលកើតឡើងក្នុងប្រជុំនៃសង្សារៈ ។

អង្គរបស់បុគ្គលទាំងនេះ ព្រះសម្ពុទ្ធទ្រង់ទូន្មានប្រដៅពុទ្ធបរិស័ទឲ្យចេះជួយសង្គ្រោះគ្នា ក្នុងវេលាដែលមានសេចក្តីទុក្ខមកគ្របសង្កត់ ដើម្បីជាសង្គហសម្បត្តិរបស់សត្វលោក ទើបទ្រង់ព្រះពុទ្ធត្រាស់ថា: “ម្នាលភិក្ខុទាំងឡាយ អ្នកណាបម្រើតថាគត អ្នកនោះឈ្មោះថាបម្រើភិក្ខុឈឺ” ក៏ថាការបម្រើជម្ងឺតែងធ្វើចិត្តឲ្យបានប្រកបដោយអង្គនោះ ។ ដូចពោលមកខាងដើមរួចហើយ បើប្រាសចាកអង្គទាំងនោះហើយ រមែងមិនបានសេចក្តីសុខចំរើនក្នុងបច្ចុប្បន្ននេះ និងអនាគតខាងមុខ ដូចជាបុរសម្នាក់ចេះវេជ្ជកម្មធ្វើពេទ្យយាងចំណានពូកែណាស់ បានមើលស្ត្រីម្នាក់ខ្វាក់ភ្នែក ឥតបានរង្វាន់អ្វីជាគ្រឿងបូជាសោះ ក៏កើតទោស-ចិត្តក្រោធខឹងប្រើឱសថថ្នាំបន្តក់ភ្នែកស្ត្រីនោះឲ្យខ្វាក់ទៅវិញ ។

ពេទ្យនោះឯង លុះឆ្លងជាតិជាលំដាប់ ក៏បានមកកើតជាព្រះចក្ខុ-បាលត្ថេរ អំពើដែលធ្វើជាវេជ្ជកម្មដោយទោសចិត្តនោះ បានឲ្យផលដល់លោកផ្តន្ទាឲ្យខ្វាក់ព្រះនេត្រទាំងសងខាង ពួកភិក្ខុទាំងឡាយ ទូលសួរព្រះសម្ពុទ្ធអំពីព្រះនេត្រព្រះចក្ខុបាលត្ថេរដែលខ្វាក់នោះ ព្រោះបានធ្វើអំពើដូចម្តេចខ្លះ? ព្រះសព្វញ្ញូបរមគ្រូទ្រង់នាំរឿងអតីតជាតករបស់ព្រះចក្ខុបាលត្ថេរជាសេចក្តីសង្ខេប ទុកគ្រាន់ជាបែបរបស់ពេទ្យដែល

មើលផ្ទឹប្រែតបដោយទោសចិត្តប្រាថ្នាតែលាភសក្ការៈ ឥតមានសេចក្ដីមេត្តាករុណាដូចតទៅនេះ ។

## កាព្យពាក្យ ៧

អតីតេយ្យកាលជ័ន្មន៍ ព្រះទៅកូនក្រុងពាកណាសី
សោយរាជសម្បត្តិក្រុងបុរី ពេញដោយពួកស្រីស្នំបំរើ ។
គ្រានោះទើបមានគ្រូពេទ្យម្នាក់ បេះពូតែជាក់ខានអំពើ
វេជ្ជកម្មដែលខ្លួនបេះមើលធ្វើ ទៅកាន់ស្រុកលើដែននិគម ។
បានជួបប្រទះនឹងស្រីម្នាក់ កើតភេតភ្នែកខ្វាក់មុខក្រៀមក្រំ
សួរថានាងឲ្យយើងផ្សំថ្នាំ ដាក់ថ្នាំបន្ដំនៅនេត្រ[១] ។
ស្រីនោះដឹកបគ្រូពេទ្យថា បើលោកមេត្តាមើលដាក់លាក់
សូមបន្តកថ្នាំលោកផ្សំដាក់ ភ្នែកខ្ញុំដែលខ្វាក់ឲ្យជាឡើង ។
គ្រូពេទ្យសួរទៅស្រីនោះថា នាងឲ្យអ្វីជារង្វាន់យើង
បើជាដូចដើមមិនសើងម៉ឹង វត្រាប់ដើងយើងដើរដើ ។
ស្រីនោះដឹកបគ្រូពេទ្យថា ខ្ញុំនឹងបុត្រាជាតាសី
នឹងនៅបំរើលោកមែនក្រែកតី បើលោកប្រណីមើលខ្ញុំជា ។
គ្រូពេទ្យតាំងផ្សំថ្នាំបន្តក់ ដាក់កូនភ្នែកផ្តុកពុំយូរយារ
តែថ្នាំមួយមុខមិនវេទនា ស្រីនោះបានជាឡើងដូចដើម ។
លុះដល់គ្រាក្រោយរក់គិតថា អញបានបេត្តាពាក្យសើម ។

---
១ ភ្នែក ។

ខ្លួនឯងតាំងក្ដួចសាច់ស្ងួតថ្មើម ជាខ្ញុំពាក្យផ្ដើមដំបូងនោះ ។
កាលណាគាត់នឹងហៅគេអញ ដោយពាក្យផ្អែមឆ្ងាញ់ជំពេះ
មុខជាជេរស្ដីពាក្យទ្រនោះ ពោតពោះឲ្យអញមិនបានទេ ។
គួរគេៗបាយបញ្ញើតគាត់ កុំឲ្យជ្រលក្លាត់ជាខ្ញុំគេ
ដោះកុនឲ្យរួចខ្លួនទេ វិះរេសម្ងំប៉ាំកុហក ។
លុះពេទ្យមកដល់ហើយសួរថា មុចទៅមេកំផ្ទាំបន្តក់
រង្គើស៊ើសគ្រាមើសបួកស្រក់ ពោលស្ដីខ្សឹកខ្សក់ករវក់ ។
ប្រាប់ថាពីដើមក្អកនឹងលួម កខ្សូវរិតទ្រមខ្លួបខ្លួបខ្វី
បកបែកល្អិតដូចដូលី ពេញទីអន្ធកាវទុក្ខវេទនា ។
ពេទ្យដឹងថាស្រីនេះធំពោត គិតចង់បន្ទោតដល់អាត្មា
មិនឲ្យរង្គាន់គាំងវេទ្យា គ្រឿងយញ្ញបូជាបន្តិចសោះ ។
អញមិនត្រូវការដោយថ្លៃឈ្នួល ស្រីនេះកំដួលឲ្យមើលគ្រោះ
ក្អកតាំងពីខ្ទាក់ស្លូឲ្យឈឺនោះ ក៏ជាគ្មានខ្លោះបៃវត់ថ្ងៃ ។
គោងធ្វើឲ្យខ្ទាក់ពេញសន្ទូច ទើបសមនឹងបួកមេបាដ្រែ
កុំឲ្យកំណាប់កក័ព្វាដៃ ទើបវិលវឹងវៃទៅដល់ផ្ទះ ។
ប្រាប់រឿងក៏វនោះដល់ប្រពន្ធ ស្ងៀមឈឹងចិត្តធ្ងន់រឹងមានះ
ប្រឹងស្ទុំថាំរួចស្រេចស្រឡះ ចេញដើរនេះនោះនាទទៅ ។
ដល់ផ្ទះស្រែខ្ទាត់ហើយប្រាប់ថា មីកំបន្តក់ថ្នាំណាពៅ

ឲ្យបួលក្នុងក្អែងនោះនោមផ្ទៅ　　គង់ទៅទឹងជាដូចប្រាថ្នា ។
ស្រែនោះមិនបានជាប្រុងគិត　　ព្រោះតែគំនិតបិត្តមិច្ឆា
លាបថ្នាំបួលដល់វង់ចក្ខុ　　មំសាក៏ក្លាយនឹតស្អុយឲ្យឈឺង ។
ឯរឿងគ្រូពេទ្យមើលរោគនេះ　　គួរតែត្រិះរិះគិតរំពឹង
ធ្វើពេទ្យទប់ចិត្តកុំឲ្យខឹង　　ប្ញប្រឹងថែទាំដោយមេត្តា ។
កុំមើលជម្ងឺប្រាថ្នាលាភ　　ផញ្ចុកផញ្ចាបគ្រឿងបូជា
គួរគិតករុណាតដល់គ្នា　　ដែលមានរោគាឈឺចុកចាប់ ។
បើមើលជម្ងឺចិត្តអាក្រក់　　ទោសៈតក់ម៉ក់ឥតខ្វិនច្បាប់
ដូចរឿងថ្ងៃនេះគួរដឹងស្រាប់　　កុំអាលប្រញាប់ប្រឡោកទទឹង ។
ព្រះសមុទ្ទគ្រាស់ទេសនា　　ឲ្យមានករុណាខ្ពស់ទទឹង
ទោសៈកើតឡើងចិត្តរឹង　　បង្ក្រាបឲ្យទឹងក្នុងសន្តាន ។
កុំឲ្យតំរើកតាមទ្វារណា　　ឈយេឬក៏ហារបើបាន
ចិត្តត្រូវខ្ជាប់ចិត្តប្រឹងរុញច្រាន　　កុំឲ្យឈ្លានពានមកខាងក្រៅ ។
ទៅធ្វើអំពើខាងអាក្រក់　　សូម្បីប៉ុនសក់គួម្ដៅ
ត្រូវឈប់សម្រាកឲ្យស្រាកនៅ　　កុំឲ្យរំផ្ដៅក្នុងឆាយា ។
ទើបឈ្មោះថាចិត្តនោះត្រជាក់　　មិនឲ្យអប្បលក្ខណ៍ដល់អាត្មា
ធ្វើការអ្វី ៗ ដូចប្រាថ្នា　　សម្រេចបរិយាកាននិទុក្ខ ។
គ្មានពៀរសេត្រូវទៅតាមទាន់　　រយពាន់កប់ជាតិតទៅមុខ

មិនខ្វាក់មិនខ្វិនរូបគ្រប់ ដោយផលចំនុកបំរុងគេ ។
កើតជាតិណា ៗ គ្មានកេរផង មិនមានសៅហ្មងក្តីខ្វះទេ
ព្រោះចិត្តខ្លួនល្អពីបុព្វេ រិះរេមើលកេរដោយករុណា ។
ចូរបោតាត់តែងប្រើចិត្តខ្លួន ឲ្យដើរសមសួនតាមមាគ៌ា
ធ្វើការអ្វីៗ មានមេត្តា ទៅតាមធម្មតាណានាំអើយ ។
បើប្រើចិត្តខ្លាំងក្លៀងកាច សុះតាមអំណាចពុំដឹងឡើយ
ហ៊ានកាប់សម្លាប់ខ្លួនឯងហើយ ពុំមានគោះគើយអង់រេក ។
នាំហេតុអាក្រក់កាឡកណ្ណី ធ្វើឲ្យគប្រែយពីបិត្តា
កំទៀរក្រៅក្រោមឥតបញ្ញា គ្មានពិចារណា ស្គាល់ខុសត្រូវ ។
ចិត្តនេះលោភប្រៀបដូចភ្លើងព្រៃ ឆេះពាលសព្វថ្ងៃត្រែគ្រប់ផ្លូវ
ពាល់តែហួសពេលផុតផ្លូវ អស់ឈើស្មៅស្បូវទៅជាផេះ ។
ហៃយុវជនទាំងប្រុសស្រី កាន់ចិត្តមេត្រីកុំរវេះ
ធ្វើការអ្វីៗ កុំធុរនេះ ដូចជាភ្លើងនេះហ្វាក់អាក់ ។
ប្រាប់លោកបុព្វណាពីព្រេងនាយ ប្រដៅសត្វសម្លាយមានមេត្តា
ឲ្យបេះស្រែឡាញ់ពប់រកគ្នា ទោះបីកាចជាក៏ឲ្យស្មើ ។
កុំឲ្យប្រែតាន់តំណាន់ស្អប់ កាយកប់លុបគុណដែលបានធ្វើ
ទោះជាគេដឹងមិនអើពើ មិនធ្វើតិះយើងកុំគួបចិត្ត ។
ទោសៈកើតឡើងបាត់សោមនស្ស អំពើទាំងអស់ផ្លូវទុច្ចរិត

ហូរចូលសន្ដានឲ្យនឹក ប្រព្រឹត្តធ្វើកម្មទៅផ្សេងៗ ។
ដូចរឿងកោកសុនខនេះ (១) ឯងមើលត្រិះរិះកុំយល់ឆ្វេង
គាត់ជាពេទ្យក្រុហមល្បែងលេង ប្រើក្មេងឲ្យចាប់សត្វពស់នោះ ។
កើតពីសេចក្ដីស្រេកឃ្លានខ្លាំង កាយអស់កម្លាំងខ្លួនញ័រខ្សោះ
តែយកអាហារបំពុមពោះ ដោយមន្ត្រពស់ស្ដោះពស់ចឹកក្មេង ។

## រឿងព្រានឈ្មោះកោកសុនខ

រឿងនេះដើមឡើយលោកនិទានអំពីព្រានម្នាក់ឈ្មោះកោកសុនខៈ ជាអ្នកប្រទុស្ដនឹងភិក្ខុ ១ អង្គដែលមិនប្រទុស្ដ ។

សេចក្ដីថា: គាត់ជាអ្នកដើរបរបាញ់សត្វ មិនបានប្រទះឃើញសត្វ បានប្រទះឃើញភិក្ខុ ១ អង្គនិមន្ដទៅបិណ្ឌបាត (និតថាឆ្កែ) គាត់ក៏ប្រទុស្ដ ពន្យុះឆ្កែឲ្យដេញខាំលោក ។ មិតរត់ឡើងទៅលើដើមឈើ ព្រាននោះក៏ចាក់បាទាអាំងគូនៃលោកចាល់តែរបូតចីវរធ្លាក់មកគ្របលើក្បាលគាត់ ។ ឆ្កែរបស់គាត់ក៏ស្មានថាជាភិក្ខុព្រួតគ្នាខាំព្រានជាម្ចាស់ស្លាប់នៅទីកន្លែងនោះទៅ ។

ព្រះដ៏មានព្រះភាគទ្រង់ប្រកាសសេចក្ដីនេះថា: កាលដែលកន្លងទៅហើយ មានពេទ្យម្នាក់ ដើរទៅក្នុងស្រុកដើម្បីធ្វើជាវេជ្ជកម្ម មិនបានមើល

១ ព្រានបណ្ដើរឆ្កែឈ្មោះកោកៈ ។

ធ្វើជម្ងឺអ្វីសោះ កើតមានសេចក្ដីស្រេកឃ្លានក៏ត្រឡប់ចេញមក ប្រទះឃើញពួកកូនក្មេងកំពុងលេងក្បែរទ្វារស្រុក ក៏មានគំនិតគិតថា: ''អញនឹងឲ្យពស់ចឹកពួកកូនក្មេងទាំងនេះ ហើយនឹងស្ដោះព្រួសយកចំណីអាហារបរិភោគ'' គាត់ក៏បង្ហាញសត្វពស់ដែលកំពុងដេកពន្លៀនក្បាលចេញមកពីក្នុងរន្ធឈើ ប្រាប់កូនក្មេងថា: នែរ៉ុយពួកកូនក្មេង! កូនសត្វសាលិកានុ៎ះហ្ន៎ ឯងចូរចាប់វាមក!

គ្រានោះ មានក្មេងម្នាក់ស្ទុះទៅចាប់ពស់ត្រង់កន្ទាប់ហើយទាញចេញផុតពីរន្ធឈើមកដឹងថាជាសត្វពស់ ក៏ស្រែកហើយក៏គ្រវែងទៅលើក្បាលពេទ្យដែលឈរជិតនៅទីនោះ ។ សត្វពស់ក៏រុំព័ទ្ធកពេទ្យហើយចឹកយ៉ាងដំណាំ ពេទ្យនោះក៏ដួលដេកស្លាប់ក្នុងទីកន្លែងនោះទៅ ។ ពេទ្យដែលមានគំនិតអាក្រក់បែបនេះ គឺកើតអំពីសេចក្ដីស្រេកឃ្លានព្រោះគ្មានអាហារបរិភោគ ហើយប្រើឧបាយប្រទុស្តបាយដល់អ្នកដទៃជួបដល់ក្ស័យជីវិតរបស់ខ្លួន ។

ចប់រឿងសង្គ្រោះមហាជនតែប៉ុណ្ណោះ ។

## សេចក្ដីដំណាល

### អំពីទេវបុត្រមារនឹងព្រះថេរៈព្រះនាមឧបគុត្ត

# មហាបុណ្ណ – សុម្ភាជិ

ប្រែចេញពីសៀវភៅសូត្រាលំការ ដ៏ជាស្នាដៃរបស់លោកអស្សឃោសៈ ដែលលោក អេឌូអារដឹហ៊្យូបែរ បានប្រែទៅជាភាសាបារាំង

(តមកនឹងចប់)

---

បោកបោះបំពោះខ្ញុំម្ចាស់សោះឡើយ ។ ចំណែកហេតុដែលខ្ញុំបានធ្វើបំពោះលោកម្ចាស់នោះជាហេតុបន្តិចបន្តួចសោះទេ ហើយលោកម្ចាស់បានធ្វើតបឲ្យខ្ញុំបានសេចក្ដីអាប់យសពន់ពេកហើយ, ពួកមនុស្ស, អសុរនិងទេវតាទាំងអស់គ្នានឹងសរហាននិន្ទាខ្ញុំម្ចាស់ពុំខាន, លោកម្ចាស់បានធ្វើឲ្យខ្ញុំអាប់ឱនខ្លួនបាត់សិរីសួស្ដីនឹងកិត្តិយស ដោយដាក់ខណ្ឌកម្ភាប់សាកសពនឹងកខ្ញុំម្ចាស់យ៉ាងនេះឯង" ។ ក្នុងខណៈនោះ ព្រះឧបគុត្តថេរ ឆ្លើយតបទៅមារាធិរាជថា: "អ្នកជាបុគ្គលអាក្រក់គួរគេតិះតិះដៀលពិតមែន ព្រោះហេតុអ្វី ក៏អ្នកយកពពួកស្រាវែកទៅប្រៀបផ្ទឹមនឹងព្រះតថាគតដូច្នោះ?" ហើយលោកពោលគាថាមានសេចក្ដីថា:

"បុគ្គលនឹងយកកល្មួយត្រាប់ទៅប្រៀបនឹងភ្នំព្រះសុមេរុម្ដេចកើត? ពន្លឺនៃអម្ពិលអម្ពែកទេ ម្ដេចឡើយទៅប្រៀបនឹងរស្មីនៃព្រះសុរិយៈ? ទឹកដែលដក់នៅក្នុងកំបង់ដៃ ចូរអ្នកកុំយកទៅប្រៀបនឹងទឹកមហាសមុទ្រ

នោះឡើយ ! ព្រះរូបកាយរបស់ព្រះតថាគតនៃអង្គនោះពេញបរិបូណ៌ដោយព្រះមហាករុណា, ព្រះបរមសាស្តា បាននាំសត្វលោកចេញពីទោសកំហុសជាអនេក ដល់អមតៈដោយសេចក្តីករុណាដ៏ធំរបស់ព្រះអង្គ ។ ចំណែកខាងអាត្មាធំខ្ញុំអង្គបានបំពេញបុណ្យកុសលខ្លះ ដើម្បីឲ្យសមតាមបំណងរបស់ព្រះលោកនាថ ។

កាលមាតុលិកជបានស្តាប់ថេរដីកានេះហើយ ក៏ពោលពាក្យជាគាថាចំពោះព្រះថេរៈជាថ្មីទៀតថា:

" សូមលោកម្ចាស់មេត្តាប្រកាសប្រាប់នូវពាក្យប្រៀនប្រដៅរបស់ព្រះតថាគតឲ្យខ្ញុំព្រះករុណាបានឮផង, ដោយនៃព្រះពុទ្ធទេសនាព្រះអង្គត្រូវត្រង់ទីនឹងទុក្ខិតបុគ្គលដែលព្រះអង្គទ្រង់បំពេញប្រយោជន៍ ដល់ពពួកសត្វនិករអមរមេឃតទៅតែគេណាស់ ។ ព្រះអង្គបានលះបង់កាមគុណនិងតណ្ហាអស់រលីងហើយ ។ ទ្រង់ជាគាំទ្រពុទ្ធផុតសេចក្តីញាប់ញ័រចំពោះលោកធម៌ទាំង ៨ ។ ខ្ញុំម្ចាស់បានយារយីព្រះអង្គជានិច្ចកាល បណ្តាលមកពីមោហៈដែលគ្របសង្កត់បិទបាំងចិត្តខ្ញុំ ចំណែកខាងព្រះអង្គទ្រង់នៅតែបំពេញបរិយាជ្ឈជាមាតានិងបិយបុត្រ" ។

ព្រះឧបគុប្តបានឆ្លើយតបចំពោះទេវបុត្តមារវិញថា: "ប្អូនអ្នកប្រីស្តាប់ពាក្យដែលអាត្មានឹងអធិប្បាយប្រាប់ដូចតទៅនេះ: "អ្នកបានធ្វើអំពើលាមកចំពោះព្រះសុគតជាញឹកញយណាស់ , ដើម្បីនឹងឲ្យអ្នកបាន

ស្អាតជ្រះស្រឡះចាកបាបកម្មទាំងនោះ ហើយបណ្ដុះកុសលកម្មក្នុងចិត្តអ្នកផង, អាត្មាឃើញថាពុំមានកិច្ចអ្វីប្រសើរគួរជាងការរំលឹកនឹកដល់គុណរបស់ព្រះសម្មាសម្ពុទ្ធ ដែលវិសេសផុតលើសលែងបុគ្គលទាំងពួងក្នុងត្រៃលោកនោះទេ", ហើយលោកសំដែងសេចក្ដីជាគាថាតទៅទៀតថា:

" អាត្មាដឹងច្បាស់ហើយថា ព្រះបរមសម្ពុទ្ធទ្រង់ឃើញកាលវេលា ព្រោះហេតុនោះហើយបានជាទ្រង់ពុំបានសំដែងសេចក្ដីស្ដីបន្ទោស ចំពោះអ្នកសោះ, ទ្រង់ជាកំពូលនៃបណ្ឌិតទាំងឡាយដ៏ឧត្ដមជាទីគោរព, ទ្រង់មានបំណងចង់ឲ្យអ្នកមានសទ្ធាជ្រះថ្លាកើតឡើងក្នុងពេលនេះឯងបានជាទ្រង់បញ្ចេញតែព្រះពុទ្ធដីកាគួរជាទីស្នេហាចំពោះអ្នក ព្រោះថាបណ្ឌិតទាំងឡាយកាលបើបានញុំាងជនដទៃឲ្យមានសទ្ធាកើតឡើងហើយ រមែងបានសេចក្ដីរីករាយសោយសុខក្នុងព្រះនិព្វាន ។ ពេលនេះអាត្មានឹងបំប្រួញសេចក្ដីយ៉ាងខ្លីបំផុតដើម្បីឲ្យអ្នកបានយល់ព្រះសទ្ធម្មថា: ទោសកំហុសគ្រប់យ៉ាងដែលអ្នកជាបុគ្គលពាលបានធ្វើកន្លងហើយ ដោយសេចក្ដីងងឹតល្ងង់ខ្លៅពោលគឺអវិជ្ជាទាំងនោះ: នោះនឹងរលាយរលត់ជ្រះស្រឡះស្អាតឡើងវិញដោយសារសទ្ធាចេតសិកដែលបានកើតមានឡើងដល់អ្នកនេះឯង" ។

ក្នុងគ្រានោះ ស្រាប់តែមានឆធិកជពីក្រោមត្រៃស្បង មានចិត្តសោមនស្សកើតឡើង ទបមាត្ស៊ូបផ្កាទើបតែហើយឆ្លើយថា: ខ្ញុំម្ចាស់បានបៀត

បៀនព្រះអង្គសព្វយ៉ាង ប៉ុន្តែបមាដូចបិយបុត្រដែលបានធ្វើខុសគ្គាំគ្គន៍កន្លងហើយ បិតាតែងអនុគ្រោះលោះលាត្រាប្រណីទោសហើយនៅទ្រទ្រង់សេចក្ដីមេត្រីស្នេហា ដ៏ធំធ្វេហៅយលើសលែងផ្ទុំប្រថពីចំពោះបុត្រនោះដដែលយ៉ាងណា ព្រះមហាឫសីក៏ទ្រង់មានទឹកព្រះហឫទ័យត្រាប្រណីទោសចំពោះខ្ញុំម្ចាស់យ៉ាងនោះដែរ ។ ប្រសិនបើបុគ្គលណាមួយបានធ្វើចិត្តរបស់ខ្លួនឲ្យប្រសប់ដោយបសាទសទ្ធាចំពោះព្រះអង្គហើយ បុគ្គលនោះនឹងធ្វើខ្លួនឲ្យជ្រះស្រឡះ អំពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តធ្ងន់ធ្ងន់កន្លងមកហើយ ហើយហេតុនោះបានដោយពិត» ។

ក្នុងពេលនោះ ទេវបុត្រមារទំប្រឹងនឹងចាំពីងពុទ្ធគុណក្នុងចិត្តចំពោះព្រះភគ្គព្រះថេរៈ ហើយទទួលយកក្រាបថ្វាយបង្គំបាទាលោកពោលថា : «លោកម្ចាស់ដ៏ចំរើនបានជួយស្រោចស្រង់ឲ្យខ្ញុំម្ចាស់មានចិត្តគោរពចំពោះព្រះបរមសម្ពុទ្ធហើយ! សូមលោកម្ចាស់ព្រមព្រះទ័យនឹងដោះរបស់ដែលព្យួរជាប់នឹងករបស់ខ្ញុំម្ចាស់ទៅ! ខ្ញុំម្ចាស់បានបៀតបៀនព្រះថេរៈពិតមែនហើយ សូមលោកម្ចាស់មេត្តាករុណាតដោះចេញទៅវិញទៅ!" ។ ព្រះថេរៈឆ្លើយតបថា : «ចាំអាត្មាធ្វើគតិជាមួយនឹងអ្នកសិនសឹមអាត្មាដោះឲ្យជាក្រោយ» ។ មារសួរថា : «គតិកានោះដូចម្ដេចទៅលោកម្ចាស់? ។ ព្រះថេរៈឆ្លើយថា: «ចាប់តាំងពីថ្ងៃនេះទៅអ្នកពុំត្រូវធ្វើទុកបុកម្នេញយាយីភិក្ខុទាំងឡាយឡើយ» ។ មារឆ្លើយថា : ខ្ញុំម្ចាស់លែងបៀតបៀនភិក្ខុ

តាំងឡាយតទៅទៀតហើយ ។ ព្រះថេរៈនិយាយទន់មាត់ថា: អ្នកដឹងស្រាប់ហើយ, អាត្មាបានចូលមកបួសក្នុងព្រះពុទ្ធសាសនា ក្រោយដែលព្រះអនាវរញ្ញាណ ទ្រង់បរិនិព្វានកន្លងទៅហើយរាង ១០០ វស្សា» ហើយលោកពោលគាថាតទៅទៀតថា: «អាត្មាបានឃើញហើយ តែព្រះធម៌កាយរបស់ព្រះត្រៃលោកនិយ្យានិកៈ, ចំណែកព្រះនិម្មាណកាយរបស់ព្រះអង្គដ៏បរិសុទ្ធផូរផង់ល្អដូចមាសជម្ពូនទ នោះអាត្មាឥតដែលបានឃើញសោះឡើយ ។ បើអ្នកពុំមានសេចក្ដីធុញទ្រាន់ចំពោះហេតុនេះទេ, សុំឲ្យអ្នកបង្ហាញឲ្យអាត្មាបានឃើញរូបកាយរបស់ព្រះអង្គផង! ព្រោះអាត្មាតែងមានសេចក្ដីស្នេហាពេញចិត្តចំពោះព្រះអង្គណាស់ ហើយចង់ឃើញរូបកាយរបស់ព្រះអង្គពន់ពេក ។

ខណៈនោះ មារពិកជបានពោលតបទៅព្រះថេរៈថា ខ្ញុំម្ចាស់ព្រមសុខចិត្តទទួលធ្វើតាមពាក្យប្រាថ្នានេះហើយ តែថាសូមលោកម្ចាស់ព្រមទទួលសន្យាថា កាលបើលោកម្ចាស់បានឃើញនិម្មាណកាយរបស់ព្រះអង្គហើយ មិនត្រូវលោកម្ចាស់គោរពនមស្ការឡើយ, សូមលោកម្ចាស់ប្រុងប្រយ័ត្នកុំបីភ្លាត់ស្មារតីក្រាបថ្វាយបង្គំចំពោះខ្ញុំដែលមានរូបកាយជាព្រះសព្វញ្ញុពុទ្ធនោះឲ្យសោះ! ទុកជាខ្ញុំប្រែក្លាយដោយរូបកាយហាក់ដូចជាព្រះបរមសាស្ដាក៏ដោយ សូមលោកម្ចាស់ប្រយ័ត្នកុំគោរពខ្ញុំម្ចាស់ឡើយ! បើលោកម្ចាស់ភ្លេចនឹកដល់ព្រះបរមគ្រូ ហើយគោរពនមស្ការចំពោះខ្លួនខ្ញុំ

កាលណា ក៏ហាក់ដូចជាលោកម្ចាស់ផុតពេលខ្ញុំជាយក្សិនកាលនោះឯង ពីព្រោះខ្ញុំម្ចាស់ពុំមែនជាអញ្ញលិកាណីយបុគ្គល ពុំមានអំណាចទីនទ្រទ្រង់នូវការគោរពនមស្សការ របស់លោកម្ចាស់ដែលជាអ្នកលះបង់កាម-គុណមកទ្រទ្រង់គេទជាបព្វជិតយ៉ាងនេះបានឡើយ ឧបមាដូចជាពន្លក ត្រួយល្ហុងខ្មែរ ដែលត្រូវដំរីបាច់កាច់បំបាក់ដោយប្រមោយហើយមែន ទ្រូបខ្ទីពុំអាចនឹងលូតលាស់ដុះដាលបានយ៉ាងណា បើខ្ញុំម្ចាស់ទទួលសេចក្តីគោរពរបស់លោកម្ចាស់ទៅហើយ ខ្ញុំម្ចាស់ក៏នឹងប្រាកដដូចជាត្រួយល្ហុងខ្មែរយ៉ាងនោះដែរ ។

ព្រះថេរៈឆ្លើយតបថា: "អាត្មាអញមិនយកអ្នកជាទីពឹងទីរឭកទេ, ចូរអ្នកធ្វើតាមគតិការនោះចុះ!» ។

ទេវបុត្រមាននិយាយតបវិញថា: «សូមលោកម្ចាស់រង់ចាំមួយរំពេចចុះ, ខ្ញុំម្ចាស់នឹងចូលទៅកាន់ព្រៃព្រៃសិន» រួចពោលពាក្យជាគាថាថា:

ពីពេលមុន ខ្ញុំម្ចាស់បាននិម្មិតខ្លួនឲ្យមានរាងកាយដូចជាព្រះពុទ្ធ មានរស្មីផ្សាយចេញមានពណ៌ដូចជាមាស ដ៏ល្អ បរិសុទ្ធគន្ធផុតពាក្យ គរហានិម្មាំងគួង ដើម្បីនឹងបញ្ឆោតគូទ្រ[១] យ៉ាងណា ខ្ញុំម្ចាស់នឹង

---

១ មានរឿងភិរម្ទួយនិយាយអំពីមារនឹងគូទ្រ ។ ក្នុងទិព្វាវទាន លោកសរសេរដោយកាន់ប្រើឈ្មោះ គ្នារី វញ្ញាយិត្តី ដែលតាមពិតនោះជាក្តេទ្រ វញ្ញយិត្តី ទើបត្រូវ ។

និម្មិតឲ្យឃើញប្រាកដយ៉ាងនោះ ក្នុងពេលនេះឯង ។ ព្រះអង្គមានរស្មីផ្សាយចេញអំពីព្រះកាយដ៏ល្អត្រកាលចន្លងបង្គួររស្មី នៃព្រះអាទិត្យនិងព្រះចន្ទ្រ, មនុស្សទាំងឡាយបានឃើញប្រាកដជាទីមានសេចក្ដីរីករាយសប្បាយ ឧបមាដូចជាបានផឹកនូវទឹកអម្ឫត ដូច្នោះឯង » ។

ព្រះថេរៈឆ្លើយតបថា: « សូមទ្រង់និម្មិតខ្លួនឲ្យល្អស័ក្តិសមដូចជាកាលព្រះអង្គទ្រង់គង់ព្រះជន្មនៅឲ្យអាត្មាបានឃើញផង ! » ។ ទេវបុត្រមារតបថា: « ករុណា លោកម្ចាស់, ខ្ញុំម្ចាស់នឹងធ្វើឥឡូវនេះឯង » ។ ខណៈនោះ ព្រះថេរៈក៏យកខ្មោចទាំងបីនោះចេញពីសាកឆ្កែ ១ រូប ស្រឡះអំពីខណ្ឌកម្មហើយ ក៏បញ្ចូលទៅក្នុងព្រៃ ព្រោះនិម្មិតខ្លួនបានដូចជាព្រះបរមគ្រូដ៏មានលំអប្រដាប់ដោយមហាបុរិសលក្ខណៈ ក្នុងពេលនោះក្លាយជារូបកាយ ដែលញុំាងនៃប្រទេសទាំងមូលឲ្យល្អរុងរឿង អ្នកផងឃើញហើយកែងមានសេចក្ដីរីករាយសប្បាយ ពុំចេះឆ្អែតឆ្អន់ក្នុងការគយគន់មើលសោះឡើយ ។ រូបកាយនៃព្រះបរមសម្ពុទ្ធដែលមារបាននិម្មិតឲ្យឃើញនោះមានឆព្វណ្ណរស្មីក្រាស់មួយព្យាមនៅស្រោបជាប់ជុំវិញ, មានព្រះសារីបុត្រស្ថិតនៅខាងស្ដាំ, ព្រះមោគ្គល្លានស្ថិតនៅខាងឆ្វេង, ព្រះអានន្ទលោកជាបច្ឆាសមណ៍ កាន់បាត្រព្រះមុនីនាថនិមន្តទៅតាមពីក្រោយ, ព្រះមហាកស្សប, ព្រះអនុរុទ្ធ, ព្រះសុភូតិនិងព្រះមហាសាវ័កឯទៀត ។ ដ៏មានចំនួនដល់ទៅមួយពាន់ពីររយហាសិបរូប

ស្ថិតនៅអមខាងត្បូងខាងស្តាំមានសណ្ឋានដូចជាឥន្ទ្រធនូ ៗ ទេវបុត្រ-មារបាននិម្មិតឲ្យឃើញ កិត្តិយសរបស់ព្រះបរមសាស្តាដោយប្រការយ៉ាងនេះឯង ហើយក៏ត្រេចត្រង់ឆ្ពោះទៅរកព្រះឧបគុប្តៈ, ព្រះថេរៈបានឃើញព្រះពុទ្ធរូបហើយក៏កើតសេចក្តីត្រេកអរក្រៃលែង ក្រោកចាកអាសនៈឈរពិនិត្យលក្ខណៈនៃមហាបុរសរបស់ព្រះអង្គ ហើយបន្ទឹ-ទានក៏ថា « ឱហ្ន៎! អនិច្ចតាធម៌ កាចអាក្រក់ណាស់ ឥតមានមេត្តាករុណាអ្វីសោះឡើយ ៗ ឱ! មិនគួរបើយ៉ាងហ្នឹងសោះ! រូបកាយរបស់ព្រះមហាមុនីដ៏មានលំអគួរអស្ចារ្យឧបមាដូចសុវណ្ណបពិត មិនសមបើនឹងរលត់រលាយបាត់ទៅវិញសោះ! អនិច្ចតាធម៌មិនគួរបើនឹងបំបាត់របស់មានសភាពបែបនេះសោះ!» ៗ ក្នុងខណៈនោះ ព្រះទ័យរបស់ព្រះថេរៈ ក៏ស្រុងស្រុះចុះទៅកាន់ពុទ្ធានុស្សតិ ហើយក៏ក្រាំងក្រុបស្មារតីនឹកគិតថា «ពេលនេះអាត្មាអញបានឃើញព្រះបរមសម្ពុទ្ធពិតប្រាកដហើយ, ទើបទុនអង្គលើកកំបង់អញ្ជលី ធ្វើដូចជាផ្កាឈូកត្រពុំប្រណម្យឡើងប-ពោល «ឱហ្ន៎! ព្រះអង្គមានលំអគួរអស្ចារ្យឥតមានខ្ចោះត្រង់ណាសោះ ព្រះភក្ត្ររបស់ព្រះអង្គល្អកន្លងលើសផ្កាឈូក ដែលលូតផុតអំពីទឹកហើយរីកស្គុះស្គាយ, ព្រះនេត្រមានពណ៌ខៀវស្រស់ល្អដូចស្លឹកនៃផ្កាឧប្បល ព្រះកាយក្រាសតាកមនិលល្អដូចជាវនប្រទេសដ៏ដេរដាសដោយបុប្ផជាតិ ព្រះអង្គគួរជាទីស្រឡាញ់ពេញត្រជាក់ចិត្តនៃអ្នកផងកន្លងលើសព្រះប(

ទឹកព្រះហឫទ័យរបស់ព្រះអង្គជ្រាលជ្រៅដូចទឹកមហាសមុទ្រ, ព្រះអង្គទ្រង់ពុំមានរំភើបញាប់ញ័រដោយលោកធម៌ទាំងប្រាំបីដូចភ្នំព្រះសុមេរុ ព្រះអង្គប្រសើរកន្លងព្រះអាទិត្យ ដោយតេជះរបស់ទ្រង់, ព្រះអង្គទ្រង់ប្រកបដោយលំនាំសមសារល្អវិសេសជាងពជសីហ៍ . ការក្រឡេកមៀងមើលរបស់ព្រះអង្គល្អស័ក្តិសមដូចឧសភរាជ , សម្បុរព្រះកាយរបស់ព្រះអង្គល្អលើសមាសទឹកដប់» ។

សេចក្តីរីករាយសប្បាយនឹងសេចក្តីគោរពរបស់ព្រះថេរៈ ក៏កាន់តែចំរើនពូនឡើងៗ ទើបលោកពន្ធ៌ពាជាគាថាយ៉ាងនេះថា:

«ឱហ្ន៎! អំពើសព្វយ៉ាង ដែលព្រះអង្គទ្រង់បានសន្សំធ្វើមកហើយនោះ សុទ្ធសឹងជាអំពើល្អបរិសុទ្ធណាស់ហើយ បានជាព្រះអង្គទ្រង់ប្រកបដោយកិត្តិយសជាផលរង្វាន់គួរអស្ចារ្យបែបនេះ គឺកុសល·កម្មដែលទ្រង់បានសន្សំពីបុព្វជាតិមកពិតដែលតាក់តែងឲ្យព្រះអង្គបានដល់នូវសភាពបែបនេះ ពុំមែនជាកម្មបច្ចុប្បន្ននេះឡើយ ។ ព្រះអង្គទ្រង់បំពេញអភិសមាចារដោយកាយដោយវាចា, ទ្រង់បំពេញទានបារមីនឹងវិរិយបារមី ទ្រង់ចំរើនឈានបង្កើតឲ្យមានបញ្ញាទ្រង់ប្រព្រឹត្តតាមផ្លូវដែលត្រូវត្រង់អស់កាលរាប់ពាន់នឹងរាប់កោដិនៃកល្ប ។ ចក្ខុរបស់មនុស្សសត្វទាំងអស់ត្រូវបាញ់ត្រង់ឆ្ពោះមករកព្រះអង្គដែលបរិសុទ្ធផុតចាកមន្ទិលទាំងពួងដោយសេចក្តីស្នេហា ។ កាលបើបានឃើញព្រះអង្គដែលទ្រ

ទ្រង់ទូន្មានបែបនេះហើយ ទុកជាសត្រូវរបស់ព្រះអង្គក៏គង់មានមេត្រីស្រឡាញ់ចំពោះព្រះអង្គវិញដែរ ។ បើនិយាយឲ្យខ្លីទៅគឺថា អាត្មាអញ, ក្នុងថ្ងៃនេះ, ត្រូវតែស្រឡាញ់និងគោរពចំពោះព្រះអង្គឲ្យណាស់ » ។

ព្រះថេរៈមានចិត្តស្ងួនស្ងុះចុះក្នុងពុទ្ធានុស្សតិបែបនេះ ហើយក៏គិតស្មានថាជាព្រះពុទ្ធពិតប្រាកដឥតមានទីកង្ខាថាជាតួទេវបុត្រនិម្មិតឲ្យឃើញឡើយ ទើបក្រោកចាកអាសនៈ ក្រញ្ញ ក្រាបវន្ទាដោយបញ្ចង្គ-ប្រតិស្ឋាន ។ ខណៈនោះ មារពាក់ជមានសេចក្ដីភ័យភិតស្រែកឡើងថា: "ភន្តេ! ព្រោះហេតុអ្វីក៏លោកម្ចាស់ធ្វើនូវពាក្យកតិកាយ៉ាងនេះ? ព្រះថេរៈសួរតបវិញថា: "អាត្មាបានទទួលពាក្យបដិញ្ញាថា ដូចម្ដេច"? ទេវបុត្រមារឆ្លើយថា: "កាលពីពេលមុន លោកម្ចាស់ បានបដិញ្ញាថា មិនគោរពក្រាបថ្វាយបង្គំខ្ញុំម្ចាស់ទេ ចុះហេតុអ្វីក៏ពេលនេះ បែរជាលោកម្ចាស់កន្លងពាក្យបដិញ្ញាមកគោរពថ្វាយបង្គំខ្ញុំម្ចាស់ទៅវិញ? ។ ព្រះថេរៈ បានស្ដាប់ពាក្យនេះហើយក៏ក្រោកអំពីផែនប្រថពីឈរឡើងពោលគាថា យ៉ាងនេះថា: «ចក្ខុរបស់អាត្មាបានសំឡឹងពិនិត្យសង្កេតព្រះកាយរបស់ព្រះបរមសម្ពុទ្ធដោយសេចក្ដីស្នេហា ហើយចិត្តរបស់អាត្មាក៏ផ្ដល់ការគោរពចំពោះព្រះអង្គដែរ ព្រោះហេតុនោះ, ដែលអាត្មាបានក្រាបសំពះដោយគោរពអម្បាញ់មិញនេះ គឺពុំមែនអាត្មាក្រាបសំពះដល់រាងកាយរបស់អ្នកទេ" ។

មាគន្ទិកជនពោលតបថា "លោកម្ចាស់បានក្រាបសំពះដោយបញ្ចង្គប្រតិស្ឋានគោរពចំពោះខ្ញុំម្ចាស់ពិតៗ ។ លោកម្ចាស់បានប្ដេជ្ញាទទឹងខ្ញុំម្ចាស់ពីពេលមុនថា: "អាត្មាទទឹងមិនធ្វើនូវសេចក្ដីគោរពចំពោះអ្នកទេ ធ្វើអ្វី?" ។ ព្រះថេរៈមានថេរដីកាចំពោះមាគន្ទិកជថា: "អាត្មាពុំមែនគោរពចំពោះអ្នកទេ, ចំណែកខាងអ្នកក៏មិនត្រូវលើងពាក្យសន្យារបស់អ្នកដែរ ។ សេចក្ដីនេះប្រៀបដូចជាព្រះពុទ្ធរូបដែលបុគ្គលបានឆ្លាក់ឡើងដោយថ្មក្ដី ឬដោយឈើដែលមនុស្សទាំងទេវតាទាំងអស់ក្នុងលោកតែងគោរពបូជានោះពុំមែនសំដៅយកថ្មឈើទេ ដែលគេគោរពនមស្ការនោះប្រាកដជាចំពោះទៅគុណព្រះបរមសាស្ដាតែម្យ៉ាង ។ អម្បាញ់មិញអាត្មាធ្វើអភិវាទនកម្មចំពោះព្រះរូបនាមរបស់ព្រះបរមសាស្ដាទេតើ អាត្មាពុំបានធ្វើអភិវាទគោរពរូបរបស់នាងទេ" ។ លុះមាគន្ទិកជបានស្ដាប់ថេរដីកាចប់សព្វគ្រប់ហើយក៏ត្រឡប់ប្រែបន្ទិកាយដូចប្រក្រតីដើមវិញ ទើបក្រញ្ញក្រាបគោរពទៀបបាទាព្រះថេរៈ ហើយក៏ត្រឡប់ទៅកាន់ទារពិកពវិញហោង ។

ខ្ញុំនាំយករឿងកាលមកជំណាលនេះ តើខ្ញុំមានបំណងដូចម្ដេច?

បើពពួកសាវករបស់ព្រះតថាគតមានប្រាថ្នាចង់ឲ្យមានបក្ខពាំងឡាយណាយផងតាមវេប្បុណ្យឲ្យបាន ដោយសេចក្ដីជ្រះថ្លាចំពោះពួកភិក្ខុ

សាមណេរក្តី, បង់ឲ្យភិក្ខុទាំងឡាយដែលបានស្តាប់ព្រះសទ្ធម្មហើយកាន់គំនិតមារយាទប្រព្រឹត្តត្រឹមត្រូវតាមផ្លូវព្រះវិន័យក្តីត្រូវសាវកទាំងឡាយនោះសំដែងធម៌ទេសនាអធិប្បាយពន្យល់នូវព្រះសទ្ធម្មដល់បរិស័ទទាំងបួនបំពូក ហើយបើសាវ័កទាំងនោះបង់សរសើរគុណរបស់ព្រះបរម-សម្ពុទ្ធត្រូវលើកយកនិទាននេះមកសំដែងចុះ ព្រោះថាមានបុគ្គលខ្លះបានកាត់ផ្តាច់ផ្តិលនូវបំណងតាមតណ្ហារូបស្រឡះដោយប្រពៃហើយតែនៅពុំទាន់ដឹងច្បាស់ ថាខ្លួនត្រូវនៅទាបចំពោះអ្នកណាឡើយ ។